# ក្រោយពីអគ្គីភ័យ

សុវត្ថិភាពពីអគ្គីភ័យជាសេចក្តីព្រួយបារម្ភសំខាន់បំផុត ចំពោះមនុស្សគ្រប់គ្នា ។ ក្រោយពីមានអគ្គីភ័យ ហើយ ជីវិតក៏ផ្លាស់ប្តូរភ្លាមៗដែរ ។ ការងើបឡើងវិញពីអគ្គីភ័យនៅផ្ទះរបស់លោកអ្នក អាចជា ដំណើរការលំបាកមួយខាងផ្លូវកាយ និងផ្លូវចិត្ត សំរាប់លោកអ្នក និងគ្រួសារ ។ ជាញឹកញាប់ណាស់ ផ្នែកមួយលំបាកជាងគេគឺការដឹងអំពីជំហានដែលលោកអ្នកត្រូវឈានហើយត្រូវទាក់ទងជាមួយអ្នកណា ខ្លះ ។

សេវាពន្លត់ភ្លើងអគ្គីភ័យ និងសេវាសង្គ្រោះ នៃស្រុក ម៉ុងហ្គោម៉ារី បានប្រមូលផ្តុំពិតមានពីការបោះពុម្ព ផ្សាយ នៃទីភ្នាក់ងារ កិច្ចចាត់ចែងការ ភាពអាសន្ន របស់សហព័ន្ធ ហើយនិងរដ្ឋបាលអគ្គីភ័យ នៃ សហរដ្ឋអាមេរិក ដើម្បីជួយលោកអ្នកក្នុងការព្យាយាមងើបឡើងក្រោយពីអគ្គីភ័យ ។ សំរាប់ អនុសាសន៍ជាច្រើន គឺតំរូវអោយមានសកម្មភ្លាមៗ នៅពេលដែលសកម្មភាព អាចត្រូវការនៅ ពេលអនាគត និងខ្លះផ្សេងទៀតត្រូវបន្តធ្វើតទៅទៀត ។

យើងផ្តល់ពិតមាននេះ ដើម្បីជួយលោកអ្នក កសាងជីវិតជាថ្មីឡើងវិញ ។ ការថែរក្សាផ្លូវអារម្មណ៍ និង ការងើបឡើងវិញ គឺសំខាន់ដូចជាការសង់ផ្ទះឡើងវិញ និងថែរក្សារបួសផ្លូវកាយអោយជា សះស្បើយ ។ សេវាពន្លត់អគ្គីភ័យ និងសេវាសង្គ្រោះ នៃស្រុកម៉ុងហ្គោម៉ារី នឹងធ្វើអ្វីៗ ដែលអាចធ្វើទៅបាន ដើម្បីជួយលោកអ្នកនៅក្នុងដំណើរការធ្វើអោយជីវិតរបស់លោកអ្នក វិលត្រលប់ទៅរកភាពធម្មតា វិញ ។ សូមលោកអ្នកមើលគេហទំព័រ របស់យើងខ្ញុំ www.mcfrs.org សំរាប់ពិតមាន និងធនធាន បន្ថែមទៀត ។

ដោយមេត្រីភាព<br>
នាយកផ្នែកពន្លត់អគ្គីភ័យ ស្រុកម៉ុងហ្គោម៉ារី

**មាតិការឿង** **ទំព័រ**


ការយល់ពីតួនាទីរបស់ក្រុមពន្លត់អគ្គីភ័យ.......

២៤ម៉ោងដំបូង......

បើលោកអ្នកមានការធានារ៉ាប់រង......

បើលោកអ្នក គ្មានការធានារ៉ាប់រង.......

ពិតមានអំពីការស្តារឡើងវិញ........

ការការពារទ្រព្យសម្បត្តិរបស់លោកអ្នក......

ការចាកចេញពីផ្ទះ.......

ការស៊ើបអង្កេតលើគ្រោះអគ្គីភ័យ......

វាយតំលៃទ្រព្យសម្បត្តិ.....

ការទូរទាត់សងការបាត់បង់.....

ភ្លើងឆេះរថយន្ត......

សត្វចិញ្ចឹម....

វត្ថុឆាប់ខូច.....

ការយល់អំពីលក្ខខណ្ឌធានារ៉ាប់រង.....

សងប្រាក់ដែលឆេះ.....

ពិតមានអំពីពន្ធដារ.......

តំរុយអំពីវត្ថុត្រូវបានមកវិញ....

ប្រតិបត្តិការក្រុមអ្នកលពន្លត់ភ្លើង-សំនួរទូទៅ.....

វិធីយកច្បាប់ចំលងរបាយការណ៍អគ្គីភ័យ......

ការប្តូរកំណត់ និងឯកសារមានតំលៃ.....

ប័ណ្ណធានារ៉ាប់រង របស់អ្នកជួល......

ក្រោយអគ្គីភ័យ-តារាងគូសឆែករបស់....

លេខទូរស័ព្ទសំខាន់ៗ.......

**ការយល់ពីតួនាទីរបស់ក្រុមអ្នកពន្លត់ភ្លើង**

ក្រសួងពន្លត់ភ្លើង ឆ្លើយតប ក្នុងស្ថានការគ្រាអាសន្ន ដើម្បីគ្រប់គ្រងពន្លត់ភ្លើង។ នៅក្នុងករណីខ្លះ គេអាចត្រូវតែសំរុកចូលដោយបង្ខំ ដែលបណ្តាយអោយមានការខូចខាតខ្លះ ដើម្បីពន្លត់ភ្លើង។ ទោះបីអគ្គីភ័យ តូច យ៉ាងណាក្តី ជាញឹកញាប់ណាស់ បញ្ចេញចំហាយភ្លើងខ្លាំង ហើយនិងផ្សែង ដែលនាំអោយអ្នកលត់ភ្លើង មានការពិបាក នឹងរកអគ្គីភ័យ នៅក្នុងអាគារ របស់លោកអ្នក រហូតដល់ពេលគេ បក់ផ្សែងចេញ និង បន្ថយកំដៅ។

ក្រសួងពន្លត់ភ្លើងនឹងបោសសំអាត ហើយបូមយកទឹកចេញ ដើម្បីធានាថា ភ្លើងរលត់ និងការពារមិនអោយមានការខូចខាតបន្ថែមទៀត។ ម្ចាស់ផ្ទះមានកាតព្វកិច្ចធ្វើសកម្មភាពបន្ថែមទៀត ចាំបាច់ ដើម្បីការពារអាគារ និងរបស់របរហួសពីវិធានការបណ្តោះអាសន្ន ដែលក្រសួងពន្លត់ភ្លើងផ្តល់អោយ ទៅទៀត។

# <u>២៤ម៉ោងដំបូង</u>

**ក្នុងករណីមានរបួសផ្ទាល់ខ្លួន**

ក្នុងករណីដែលលោកអ្នក មិត្តភ័ក្រ្ត ឬសមាជិកគ្រួសាររបួសដោយសារអគ្គីភ័យ លោកអ្នកគួរធ្វើតាម ទំរង់ការខ្លះៗ បើរបួសតំរូវអោយ លោកអ្នកព្យាបាលរបួសបណ្តោះអាសន្នភ្លាមៗ។ ទាក់ទងនឹងអ្នក ដែលជួលលោកអ្នក បើលោកអ្នកមានប័ណ្ណធានាសុខភាព ឬក៏ប័ណ្ណធានារ៉ាប់រងសុខភាព ឬក៏ ភ្នាក់ ងារក្រុមហ៊ុននេះ បើជាប័ណ្ណធានារ៉ាប់រង របស់លោកអ្នកផ្ទាល់។ ប័ណ្ណធានារ៉ាប់រងជាផ្នែកមួយ របស់ ម្ចាស់កម្មសិទ្ធផ្ទះ ដែលអាចសងថ្លៃពេទ្យ មានកំរិតសំរាប់មនុស្សណាដែលរបួសនៅក្នុងផ្ទះ របស់ លោកអ្នក ហើយដែលមិនមែនជាសមាជិកគ្រួសារជិតរបស់លោកអ្នក។ ប័ណ្ណធានារ៉ាប់រងរបស់ម្ចាស់ កម្មសិទ្ធផ្ទះ អាច សងលោកអ្នកក្នុងករណីមានពាក្យបណ្តឹង ទទួលខុសត្រូវអោយលោកអ្នក សង ដោយសារតែអគ្គីភ័យ។ សូម ទាក់ទងនឹងភ្នាក់ងារក្រុមហ៊ុនធានារ៉ាប់រង សំរាប់ពិតមាន បន្ថែម ទៀត។

# ពិតមានអំពីប័ណ្ណធានារ៉ាប់រង

## បើលោកអ្នកមានប័ណ្ណធានារ៉ាប់រង

បើលោកអ្នកមានប័ណ្ណធានារ៉ាប់រង ប័ណ្ណធានារ៉ាប់រងរបស់លោកអ្នក នឹងជាកត្តាតែមួយគត់ ដែលសំខាន់ជាងគេក្នុងការសងការខូចខាតដោយអគ្គីភ័យ ។ អ្នកធានារ៉ាប់រងទូទាត់សង អាចជួយ លោកអ្នកបានក្នុងការជួសជុលភ្លាមៗ ឬជួយលោកអ្នកអោយផ្ទះលោកអ្នកមានសុវត្ថិភាព ។ បើលោកអ្នកមិនអាចទាក់ទងជាមួយភ្នាក់ងាររបស់ លោកអ្នកបានទេ ហើយត្រូវការអ្នកមានវិជ្ជា ជីវៈ ជួយវាយក្តារផ្ចិតផ្ទះរបស់លោកអ្នកនោះ លោកអ្នកអាចទាក់ទងនឹងអ្នកម៉ៅការ ឬក្រុមហ៊ុន ស្តារការខូចខាត ។ ជាការសំខាន់ ជាអាយុជីវិត ដែលលោកអ្នកគួរសំរបសំរួល ជាមួយអ្នក ធានារ៉ាប់ងទូទាត់សងជាមុនសិន មុននឹងចុះកុងត្រាទទួលយកសេវាម៉ៅការទទួលការស្តារណាមួយ ។ លោកអ្នកអាចរំលោភលើការទទួលខុសត្រូវរបស់អ្នកធានារ៉ាប់រង ដោយទទួលអ្នកម៉ៅការ ដោយគេមិនបានដឹង ឬយល់ព្រម ។ សួរក្រុមហ៊ុនធានារ៉ាប់រង របស់លោកអ្នក អំពីតម្រូវការក្នុងផ្ទះដូចជា តើត្រូវការបិទស្រោបទ្វារ បង្អួច ហើយនិងទីកន្លែងចំហរ ដ៏ទៃទៀត ហើយបូមយកទឹកចេញ ។

សួរយោបល់ក្រុមហ៊ុនធានារ៉ាប់រង របស់លោកអ្នកអំពីអ្វីដែលលោកអ្នកត្រូវធ្វើ ។ អ្នកមានប័ណ្ណធានារ៉ាប់រងខ្លះអាចត្រូវការឱ្យធ្វើបញ្ជីរសារពើភ័ណ្ឌ នៃវត្ថុផ្ទាល់ខ្លួន ដែលខូចខាត ដោយបង្ហាញយ៉ាងលំអិត អំពីគុណភាព រូបរាង ហើយនិងតំលៃដែលលោកអ្នកទិញវត្ថុនោះ ។

យកការធានារ៉ាប់រងរបស់អ្នកជួលផ្ទះ ឬរបស់ទ្រព្យ ។ ការមានអារម្មណ៏ខុសពីបណ្តាអ្នកជួលផ្ទះគេគឺៈ ប័ណ្ណធានារ៉ាប់រងរបស់ម្ចាស់ផ្ទះ នឹងសងគេ ។ ទោះបីជាម្ចាស់ផ្ទះតែងតែមានប័ណ្ណធានារ៉ាប់រងក៏ដោយ ក៏គេគ្រាន់តែធានារ៉ាប់រងលើអាគារ ទល់នឹងការខូចខាតប៉ុណ្ណោះទេ ។ ប័ណ្ណធានារ៉ាប់រងរបស់គេ មិនសងទ្រព្យសម្បត្តិផ្ទាល់ខ្លួន នៅក្នុងផ្ទះ បន្ទប់ជួលរបស់លោកអ្នកទេ ។ ប័ណ្ណធានារ៉ាប់រងមួយចំនួន មានសំរាប់ម្ចាស់ផ្ទះ អ្នកជួល ឬម្ចាស់ផ្ទះកុនដូ ។ យើងស្នើជូន យោបល់ ជាដាច់ខាតអោយអ្នក រុករកជំរើស ហើយជ្រើសរើយយកប័ណ្ណណាដែលល្អសំរាប់លោកអ្នក ។

ប័ណ្ណធានារ៉ាប់រង របស់លោកអ្នកជាកិច្ចសន្យារវាងលោកអ្នក ហើយនិងអ្នកលក់ប័ណ្ណធានារ៉ាប់រង ។ ការទទួលខុសត្រូវរបស់លោកអ្នកក្រោយពីការខូចខាត ដោយអគ្គីភ័យមានដូចតទៅៈ

- **ផ្ញើកំណត់ហេតុភ្លាម១អំពីការខាតបង់ ទៅអោយក្រុមហ៊ុនធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រង ឬជើងសារជំនួញ ។**
- ការពារទ្រព្យសម្បត្តិកុំអោយខូចខាតថែមទៀត ដោយជួសជុលជាចាំបាច់ ឬដាក់ស្តែងដូច ជាបាំងប្រហោងនៅដំបូល ឬជញ្ជាំង ។
- ប្រុងប្រយ័ត្នដោយថៅកគួរសមកុំអោយខូចខាត ដូចជាបង្ហូរទឹកពីបំពង់ទឹក នៅរដូវរងារ បើគ្មានម៉ាស៊ីនកំដៅផ្ទះមួយរយៈពេលយូរ ។ ក្រុមហ៊ុនធានារ៉ាប់រងអាចប្រកែកមិនព្រមសងការខូចខាត ដែលកើតមានឡើង ដោយមិនបានថែរក្សា ដោយសមហេតុផលដូច្នេះ ។
- ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលខូចខាត ដោយល្អិតល្អន់ទាក់ទិននឹងចំនួន រូបរាង តំលៃទិញថ្លៃដើម ថ្ងៃខែទិញ ប៉ាន់ស្មានការខូចខាត នឹងតំលៃសង ។ គិតគួរអំពីការថតរូប ឬ ថតវីដេអូនូវការខូចខាត នៅទីកន្លែងកើតឡើងសំរាប់ការកត់ត្រាទុកដើម្បីជាភស្តុតាងទាមទារឱ្យសង ។
- សហប្រតិបត្តិការជាមួយអ្នកធានារ៉ាប់រង ឬអ្នកទូទាត់សង របស់គេដោយរក្សាទុកបង្ហាញទ្រព្យសម្បត្តិខូចខាត អោយមន្ត្រីធានារ៉ាប់រង ។
- ទុកច្បាប់ចំលងឯកសារ និងរូបថតទាំងអស់ដែលលោកអ្នកអោយទៅអ្នកទូទាត់សង ឬក្រុមហ៊ុនធានារ៉ាប់រង សំរាប់បញ្ជីរបស់លោកអ្នក ។

លោកអ្នកក៏ត្រូវការធ្វើ**សេចក្តីរាយការណ៍ជាផ្លូវការ** អំពីការខូចខាតដែរ នៅក្នុងរយៈពេលថ្លែង ស្រាប់ ។ សេចក្តីរាយការណ៍តាមធម្មតាមានដូចជាៈ

- ពេលវេលា និងមូលហេតុនៃការខូចខាត
- ឈ្មោះនិងអាស័យដ្ឋានរបស់លោកអ្នកដែលជាប់ទាក់ទិននឹងទ្រព្យសម្បត្តិនោះ ។ អ្នកទាំង នោះមានដូចជាៈ អ្នកមានម៉ហ្គេតប្តី ឬប្រពន្ធ នៅដាច់គ្នា ឬលែងលះគ្នា ឬអ្នកមានសិទ្ធិយកទ្រព្យកូន បំណុល ។
- ផែនទីសំណង់ និងលក្ខណៈពិសេសរបស់ផ្ទះចាស់ ហើយនិងការប៉ាន់ស្មានលំអិត សំរាប់ជួសជុល ។

# ការប៉ាន់ស្មានការខូចខាតដោយអគ្គីភ័យ

ក្រសួងពន្លត់អគ្គីភ័យ និងសេវាសង្គ្រោះ នៃស្រុកម៉ុងហ្គោម៉ារី នឹងជូនដំណឹងទៅក្រសួងផ្ទះសំបែង បើផ្ទះរបស់លោកអ្នកត្រូវខូចខាត ដោយសារអគ្គីភ័យ ។ ក្រសួងអធិការកិច្ច អាជ្ញាប័ណ្ណនិងលិខិតអនុញ្ញាត្តិ និងឆែកមើលផ្ទះរបស់លោកអ្នក ដើម្បីកំណត់ទំហំ ការខូចខាតដោយអគ្គីភ័យ ហើយនិងលិខិតអនុញ្ញាត្តិអ្វីខ្លះដែលត្រូវមានដើម្បីជួសជុលវា ។ មុននឹងជួសជុលអ្វី សូមទាក់ទងនឹងក្រសួងអធិការកិច្ច អជ្ញាប័ណ្ណ និងលិខិតអនុញ្ញាត្តិ ហើយធ្វើអោយជាក់លាក់ថាគេដឹងថា ជាការខូចខាតដោយអគ្គីភ័យ ដើម្បីអោគេធ្វើលិខិតអនុញ្ញាត្តិអោយបានលឿន ។ លោកអ្នកត្រូវសំរបសំរួលការជួសជុលជាមុន ជាមួយក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកសិន ។

# រកទីកន្លែងអោយគ្រួសាររបស់លោកអ្នកស្នាក់នៅ

បើផ្ទះរបស់លោកអ្នកនៅមិនបានហើយលោកអ្នកមិនអាចរកទីកន្លែងនៅទៀន ដូចជា ជាមួយគ្រួសារ ឬ មិត្តភ័ក្រ្ត សូមសួរយោបល់ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកអោយដឹងថាតើ គេចេញមុខចំណាយក្នុង ការរស់នៅបន្ថែមអោយលោកអ្នកដែរឬទេ ។ អង្គការកាកបាទក្រហមអាចមានលទ្ធភាពផ្តល់ទីជំរក បណ្តោះអាសន្នអោយលោកអ្នករហូតដល់លោកអ្នកអាចរៀបចំជួលទីកន្លែងមួយសំរាប់ស្នាក់នៅ ។

# សេវាស្តារឡើងវិញ

លោកអ្នក ឬអ្នកធានារ៉ាប់រងលោកអ្នក អាចជួលសេវាក្រុមហ៊ុនស្តារ ការខូចខាតដោយអគ្គីភ័យ ឡើងវិញ ។ ជាការសំខាន់ណាស់ ដែលលោកអ្នកសំរបសំរួល ជាមួយក្រុមហ៊ុនធានារ៉ាប់រង ឬអ្នក ទូទាត់សង មុនម៉ៅការសេវាជួសជុលណាមួយ ។ បើលោកអ្នកឈ្លានពានទៅក្នុងផ្នែកណា ដែលអ្នកធានា រ៉ាប់រងទទួលខុសត្រូវ ដោយម៉ៅការសេវាដោយគេមិនបានដឹង ឬយល់ព្រម លោកអ្នកអាចត្រូវសង លិខិតរាយមុខប្រាក់បំណុលដែលតាមធម្មតា អ្នកធានារ៉ាប់រងត្រូវសង ។

ឆែកមើលសំបុត្រសំអាង មុននឹងជួលក្រុមហ៊ុនណាមួយអោយជួសជុល ។ ក្រុមហ៊ុនទាំងនេះផ្តល់ សេវាមួយចំនួនធំ ដែលអាចមានរួមទាំងសេវាខ្លះ ឬសេវាទាំងអស់ដូចខាងក្រោមនេះ:

- ធានារ៉ាប់រងកុំអោយផ្ទះខូចខាតច្រើនថែមទៀត
- វាស់វែងមើលរចនាសម្ព័ន្ធខូចខាត
- រជួសជុលរចនាសម្ព័ន្ធខូចខាត
- ប៉ាន់ស្មានតំលៃជួសជុល ឬផ្លាស់វត្ថុនៃទ្រព្យសម្បត្តិផ្ទាល់ខ្លួនជាថ្មី
- ខ្ចប់ ដឹកជញ្ជូន ហើយទុកវត្ថុក្នុងផ្ទះនៅក្នុងឃ្លាំង
- រ៉ាប់រងអោយមានការបោសសំអាតត្រឹមត្រូវ ឬអ្នកម៉ៅការបន្តសំរាប់ជួសជុល
- រក្សាទុកវត្ថុជួសជុលហើយ ទំរាំដល់ពេលត្រូវការ

# ការពារទ្រព្យសម្បត្តិរបស់លោកអ្នក

លោកអ្នកត្រូវតែផ្តល់ការថែរក្សាសមហេតុផល ដើម្បីការពារទ្រព្យសម្បត្តិ ផ្ទាល់ខ្លួនរបស់លោកអ្នក ដែលនៅសេសសល់ ដើម្បីអោយប័ណ្ណធានារ៉ាប់រងរបស់លោកអ្នកនៅតែមានប្រសិទ្ធិភាពដដែល ។ វាយក្តារភ្ជាប់បង្អួច និងទ្វារ បើវាខូចខាត ហើយបិទប្រហោងដំបូល ជាមួយបន្ទះក្តារ ក្រណាត់សំរាប់ ការពារវត្ថុ ឬក្រដាសលាបជ័រ ។ បើធាតុអាកាសត្រជាក់ ធ្វើអោយជាក់ថាប្រព័ន្ធបំពង់ទឹក ឬឧស្ម័ន ទាំងអស់ ត្រូវបិទហើយយកទឹកចេញ ។ ទាក់ទងនឹងក្រុមហ៊ុនឧស្ម័នឱ្យឆែកមើលប្រដាប់ប្រដា ប្រើប្រាស់ក្នុងផ្ទះ កុំឱ្យមានគ្រោះថ្នាក់ ដូចជាចង្ក្រាន ឬចង្ក្រានប្រើអគ្គិសនី ឬឧស្ម័ន គ្រឿងកំដៅទឹក និងឡដុតកំដៅផ្ទះ ។ ទាក់ទងនឹងជាងតភ្លើង មានឈ្មោះល្អ ឱ្យឆែកមើលគ្រឿងឧបករណ៍ប្រើភ្លើង ហើយនិងខ្សែភ្លើងទាំងអស់កុំឱ្យមានគ្រោះថ្នាក់ ហើយអាចប្រើបានមុននឹងតខ្សែវាឡើងវិញ ។ បើអ្នក ពន្លត់ភ្លើងត្រូវដកកុងទ័រ ឬផ្តាច់មិនឱ្យប្រើ គួរទាក់ទងជាមួយក្រុមហ៊ុនអគ្គិសនី ឬឱ្យជាងត ភ្លើង ជួសជុលវា ។

គួរបញ្ជាក់ឱ្យច្បាស់អំពីការសំរបសំរួលសេវាទាំងអស់ទុកជាមុន ជាមួយក្រុមហ៊ុន ធា នារ៉ាប់រងរបស់ លោកអ្នក ឬអ្នកទូទាត់សង ។ បើគេទារប្រាក់ឱ្យសងថ្លៃសេវាទាំងអស់នោះ រក្សាទុក បង្កាន់ដៃ ធ្វើជា ភស្តុតាង នៃប្រាក់ដែលចាយទាក់ទងនឹងការខូចខាត ដោយសារអគ្គីភ័យ ។ ធ្វើដូច្នេះនឹងជួយ ផ្ទៀង ផ្ទាត់ការខូចខាតដែលលោកអ្នក ដាក់ក្នុងមុខចំណាយ នៅក្នុងក្រដាសបំពេញពន្ធប្រាក់ចំណូល ។

# បើលោកអ្នកគ្មានការធានារ៉ាប់រងទេ

បើទ្រព្យសម្បត្តិរបស់លោកអ្នកគ្មានការធានារ៉ាប់រងទេ ឬបើការធានារ៉ាប់រងរបស់លោកអ្នកមិនសង ការបាត់បង់ទាំងអស់របស់លោកអ្នកទេ ទាក់ទងនឹងមេធាវីប្រចាំគ្រួសាររបស់លោកអ្នក ឬសេវាប្រាក់ ចំណូល Internal Revenue Service សុំការណែនាំ។ លោកអ្នកអាចមានសិទ្ធិទទួលការ ខាតបង់ដោយសារគ្រោះថ្នាក់។ ទាក់ទងនឹងការិយាល័យ Internal Revenue Service Office ហើយសុំឯកសារផ្សព្វផ្សាយលេខ៥៧៤ស្តីអំពីពិតមានពន្ធដា ដោយគ្រោះមហន្តរាយ ការបាត់បង់ដោយគ្រោះថ្នាក់ ហើយនិងការលួចប្លន់ **Publications 574 Tax Information on Disasters, Casualty Losses and Thefts**។

បើលោកអ្នកគ្មានការធានារ៉ាប់រង ហើយត្រូវការជំនួយ ទាក់ទងនឹងសេវាសង្គ្រោះមហន្តរាយ ក្នុង តំបន់សុំជំនួយ។ អង្គការកាកបាទក្រហមអាមេរិកដែលមានស្រាប់ ដើម្បីជួយលោកអ្នក ២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង ១សប្តាហ៍។ អង្គការនេះអាចជួយបំពេញសេចក្តីត្រូវការភ្លាម១របស់លោកអ្នក ផងដែរ ដូចជាម្ហូប ខោអាវ និងផ្ទះជ្រក ហើយរកទីភ្នាក់ងារដែលអាចជួយលោកអ្នក មកពីសហគមន៍របស់ លោកអ្នក។

អង្គការឯកជនដែលអាចធ្វើជាប្រភពជំនួយ ឬពិតមាន:

- →អង្គការកាកបាទក្រហម (American Red Cross)
- →អង្គការកងទ័ពសង្គ្រោះ (Salvation Army)
- →អង្គការសាសនា
- →ក្រសួងសង្គមកិច្ច
- →អង្គការរបស់ទីក្រុង
- →ការិយាល័យសេវាគ្រាអាសន្នរបស់រដ្ឋ ឬទីក្រុងដែលអ្នករស់នៅ
- →មជ្ឈមណ្ឌលមិនយកកំរៃណែនាំខាងវិបត្តិផ្លូវចិត្ត

# កម្មវិធីជំនួយ/សំរាប់ជួយភ្លាមៗដោយសមានចិត្ត

ខាងក្រោមនេះគឺជាបញ្ជីរាយឈ្មោះកម្មវិធីស្ម័គ្រចិត្តផ្តល់ម្ហូបអាហារ ។ កម្មវិធីខ្លះផ្តល់យានដឹកនាំ គ្រឿងសង្ហារឹម ខោអាវ តុទូ និងជំនួយជាប្រាក់ ។ FISH មានន័យថា For Immediate Sympathetic Help ឬសំរាប់ជួយភ្លាមៗ ដោយសមានចិត្ត ។ គឺមានបំរើនៅស្រុក ម៉ុងហ្គោម៉ឺរី ភាគខាង ជើង ខាងលិច ដូចជា តំបន់ Poolesville, Boyds, Dickerson, Beallsville និង Barnesville ។

| FISH<br>For Immediate Sympathetic Help | |
|---|---|
| **Leisure World FISH** | 301-598-1345 |
| **Rockville FISH** | 301-564-0800 |

| HELP | |
|---|---|
| **Bethesda HELP** | 301-294-4888 |
| **Damascus HELP** | 301-253-4100 |
| **Gaithersburg HELP** | 301-216-2510 |
| **Germantown HELP** | 301-482-1320 |
| **Olney HELP** | 301-774-4334 |
| **Silvery Spring-Wheaton HELP** | 301-585-4357 |
| **WUMCO HELP** | 301-972-8481 |

# ការប្រុងប្រយ័ត្នដ៏សំខាន់ៗ

→**កុំចូលទៅក្នុងទីកន្លែងខូចខាត**។ សួរក្រសួងពន្លត់អគ្គីភ័យជាមុនសិន ដើម្បីឱ្យជាក់ថាផ្ទះរបស់លោកអ្នកមានសុវត្ថិភាព។ កុំកាត់ ឬដើរកាត់ខ្សែបន្ទះស្តើងៗ មានពិណដាក់លើទ្វារ ឬបង្គួចសំគាល់កន្លែងខូចខាត លើកលែងតែអាជ្ញាធរតំបន់ជូនយោបល់ថា គ្មានគ្រោះថ្នាក់ទេ។ សុំចងចាំថា ភ្លើងអាចឆេះឡើងវិញបាន ពីគំនរកំទេចឆេះងំ មើលមិនឃើញ។

→តាមធម្មតា ក្រសួងពន្លត់អគ្គីភ័យនឹងធានាឱ្យជាក់ថា គ្រឿងប្រើប្រាស់ដូចជា ទឹក ភ្លើងអគ្គិសនី និងឧស្ម័នធម្មជាតិ ប្រើបានដោយគ្មានគ្រោះថ្នាក់ ឬត្រូវបិទ មុនគេចេញពីផ្ទះ របស់លោកអ្នក។ កុំបើកទឹក ភ្លើង ឧស្ម័ន ដោយខ្លួនឯង។

→ពិនិត្យមើលរចនាសម្ព័ន្ធខូចខាតដោយសារអគ្គីភ័យ។ ទ្វារ ហើយនិងក្តារអាចខូចខាត ហើយ រងគ្រោះដោយអាចរលំបាន។

→ម្ហូបអាហារ ភេសជ្ជៈ ហើយនិងថ្នាំ ដែលត្រូវចំហាយក្តៅ ផ្សែង ម្រែងភ្លើង និងទឹក មិនត្រូវ បរិភោគទេ។

# ការចេញពីផ្ទះ

គួរទាក់ទងនឹង ក្រសួងនគរបាលក្នុងស្រុក ដើម្បីប្រាប់គេ អំពីផ្ទះ ដែលទុកចោលគ្មានមនុស្សនៅ។ ក្នុង ករណីខ្លះអាចជាការចាំបាច់ វាយភ្ជិតអ្វីៗ នៅចំហរ កុំឱ្យមនុស្សចូលក្នុងតំបន់ហាមឃាត់។ រក្សាទុក ឱ្យគង់ បង្កាន់ដៃប្រាក់បង់ចំណាយ ក្រោយពីឧប្បត្តិហេតុ។ បង្កាន់ដៃសំខាន់ណាស់ក្នុងការបង្ហាញ ក្រុមហ៊ុនធានារ៉ាប់រង នូវប្រាក់ដែលលោកអ្នកចាយទាក់ទងនឹង ការខាតបង់ដោយអគ្គីភ័យ ហើយនិងផ្ទៀងផ្ទាត់ការខាតបង់ ដែលលោកអ្នកដាក់ឱ្យរួចពន្ធដារ ក្នុងក្រដាសបង់ពន្ធដារ។

**បើធ្វើទៅគ្មានគ្រោះថ្នាក់ទេ ព្យាយាមរកមើលវត្ថុខាងក្រោមនេះ:**

→ប័ណ្ណសំគាល់ខ្លួន ដូចជាប័ណ្ណបើកបររថយន្ត ហើយនិងប័ណ្ណសន្តិសុខសង្គម

→ពិតមានអំពីការធានារ៉ាប់រង

→ពិតមានអំពីការប្រើថ្នាំ

→វ៉ែនតា ប្រដាប់ពាក់ឱ្យឮ ឬប្រដាប់សិប្បនិមិតផ្សេងទៀត

→វត្ថុមានតំលៃដូចជាប័ណ្ណទិញជឿ សៀវភៅធនាគារ សាច់ប្រាក់ គ្រឿងអលង្ការ

មានមនុស្ស និងអង្គភាពជាច្រើនដែលលោកអ្នកត្រូវប្រាប់គេអំពី ការផ្លាស់ប្តូរទីលំនៅ ទៅកន្លែងថ្មី។ អ្នកទាំងនេះមានជាអាទិ៍:

-ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នក

-ក្រុមហ៊ុនខ្ចីប្រាក់សំរាប់បង់ថ្លៃផ្ទះរបស់លោកអ្នក

-គ្រួសារ មិត្តភ័ក្រ្ត និងអ្នកជិតខាងរបស់លោកអ្នក

-អ្នកជួលលោកអ្នកឱ្យធ្វើការ

-សាលារៀនរបស់កូន

-ប្រៃសណីយ៍

-សេវាដឹកជញ្ជូនផ្សេងៗ

-ក្រសួងពន្លត់អគ្គីភ័យ និងនគរបាល របស់លោកអ្នក

-ក្រុមហ៊ុនភ្លើងអគ្គិសនី ទឹក ឧស្ម័នរបស់លោកអ្នក

# ការស៊ើបអង្កេតគ្រោះអគ្គីភ័យ

បើការិយាល័យតំរួតអគ្គីភ័យ នគរបាលស្រុកម៉ុងហ្គោម៉ឺរី ឬក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នក កំពុងតែធ្វើការស៊ើបអង្កេត អំពីអគ្គីភ័យដែលលោកអ្នករងគ្រោះ គួរសួរយោបល់ពួកគេសិន មុនផ្លាស់ចេញ ឬផ្លាស់ប្តូរទីកន្លែងវត្ថុ នៅក្នុងផ្ទះ ឬរថយន្តរបស់លោកអ្នក។

# ការវាយតំលៃផ្ទះរបស់លោកអ្នក

បញ្ជីសារពើភ័ណ្ឌ មុនអគ្គីភ័យ ព្រមជាមួយនឹងខ្សែអាត់វីដេអូ អំពីទ្រព្យសម្បត្តិទាំងអស់របស់ លោកអ្នក អាចបង្ហាញឱ្យឃើញថា ជាឯកសារមានតំលៃ នៅពេលដែលលោកអ្នកទាវឱ្យគេសង។

# ការទូរទាត់សងការបាត់បង់

ការទូរទាត់សងការបាត់បង់ ជាដំណើរការនៃការដាក់តំលៃលើទ្រព្យសម្បត្តិ ដែលខូចខាត ។ នេះជាលទ្ធផលនៃការព្យាយាមរួម ពីបណ្តាភាគីជាច្រើន ។ ភាគីជាមូលដ្ឋាននៃដំណើរការនេះគឺម្ចាស់ផ្ទះ ឬ អ្នកនៅក្នុងផ្ទះ ក្រុមហ៊ុនធានារ៉ាប់រង និងអ្នកតំណាងក្រុមហ៊ុន ។

តាមធម្មតាក្រុមហ៊ុនធានារ៉ាប់រង តំរូវឱ្យម្ចាស់ផ្ទះ និងអ្នករស់នៅក្នុងផ្ទះធ្វើបញ្ជីសារពើភ័ណ្ឌ ហើយសហ ការនៅក្នុងដំណើរការវាយតំលៃនៃការខូចខាត ។ ភ្នាក់ងារធានារ៉ាប់រងអាចដើរតួនាទីជាអ្នក ទូទាត់សង បើការខាតបង់មានទំហំតូច ។ អ្នកធានារ៉ាប់រងអាចបញ្ជូនអ្នកទូទាត់សង បើការខាតបង់ មានទំហំតូច ។ អ្នកធានារ៉ាប់រងអាចបញ្ជូនអ្នកទូទាត់សង ដែលជាសមាជិកអចិន្ត្រៃយ៍នៃបុគ្គលិក របស់អ្នកធានារ៉ាប់រង ឬក្រុមហ៊ុនអាចជួល អ្នកទូទាត់សងឯករាជ្យឱ្យធ្វើកិច្ចការ តាងនាមខ្លួន ។ គឺជា កិច្ចការរបស់អ្នកទូទាត់សង ធានារ៉ាប់រង ក្នុងនាមខ្លួនជាអ្នកតំណាងក្រុមហ៊ុនធានារ៉ាប់រង តាមដានមើល ហើយជួយក្នុងដំណើរការឱ្យតំលៃលើការបាត់បង់ ហើយនិងការទូទាត់សំរុះសំរួល ដោយ យុត្តិធម និងប្រកបដោយសមធម សងការខូចខាតនោះ ។

-កុំបោះចោលវត្ថុខូចខាត រហូតទៅដល់ពេលក្រោយការធ្វើបញ្ជីសារពើភ័ណ្ឌហើយ ។ គេគិតគួរបញ្ចូលការខូចខាតទាំងអស់ នៅក្នុងសំបុត្រទាមទារឱ្យក្រុមហ៊ុនធានារ៉ាប់រងសង ។

-សូមពិភាក្សាផែនការរបស់លោកអ្នកជាមួយនឹង ភ្នាក់ងារ រឺ ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកជាមុនសិន  មុននឹងចុះកុងត្រា ក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌ រឺការជួសជុលណាមួយ ។

# រថយន្តត្រូវភ្លើងឆេះ

## បើមានការធានារ៉ាប់រង

ទាក់ទងនឹងភ្នាក់ងារ ធានារ៉ាប់រងរបស់លោកអ្នក ។ ពួកគេអាចពន្យល់អំពីទំហំ នៃការសងលោកអ្នក ហើយជួយលោកអ្នកអំពីការទារឱ្យសង ។ បើរថយន្តរបស់លោកអ្នកឆេះខូចខាត ដោយអគ្គីភ័យឆេះតួ រថយន្ត គួរទាក់ទង នឹងភ្នាក់ងារធានារ៉ាប់រងផ្ទះ និងរថយន្ត ។

# បើគ្មានការធានារ៉ាប់រង

បើរថយន្តអាចជួសជុលបាន មានបញ្ជីរាយឈ្មោះទីកន្លែងជួសជុលនៅក្នុងសៀវភៅទូរស័ព្ទទំព័រលឿង សៀវភៅរាយឈ្មោះ ទីលំនៅ និងទូរស័ព្ទក្រោមចំណងជើងជួសជុលរថយន្ត និងសេវា Automobile Repair and Sevice។

បើត្រូវឱ្យទាញអូសរថយន្ត សូមមើលទំព័រនៅក្នុងសៀវភៅលឿងរាយឈ្មោះទីលំនៅ និងទូរស័ព្ទក្រោម ចំណងជើង ថា្យសេវាផ្លូវថ្នល់រថយន្ត ឬហៅថា Automobile Road Service ឬសួរយោបល់ ភ្នាក់ងាររ៉ាប់រង របស់លោកអ្នក ក្នុងករណីប័ណ្ណធានារ៉ាប់រង របស់លោកអ្នកចេញថ្លៃការអូសរថយន្ត ឬចេញថ្លៃលើការត្រូវការជាក់លាក់ណាមួយ ។

បើរថយន្តខូចខាតជួសជុលមិនបាន វាអាចមានតំលៃខ្លះនៅទីកន្លែងយកគ្រឿងរថយន្តមិនខូចមក វិញ។ បញ្ជីរាយឈ្មោះក្រុមហ៊ុនយកគ្រឿងរថយន្តមិនខូចមកវិញ មាននៅក្នុងសៀវភៅទំព័រលឿង នៅក្នុងសៀវភៅរាយឈ្មោះ ទីលំនៅ និងទូរស័ព្ទក្រោមចំណងជើង យកគ្រឿងរថយន្តមិនខូចមកវិញ ឬហៅថា Automobile Salvage។

# ប្រតិបត្តិការរបស់ក្រសួងពន្លត់អគ្គីភ័យ និងទំរង់បែបបទសំរាប់រថយន្ត

ជួនកាលអ្នកពន្លត់ភ្លើងត្រូវការទំលាយចូលទៅក្នុងរថយន្តដោយបង្ខំ។ ការងារនេះ ជាការចាំបាច់ ពីព្រោះ គេត្រូវការឆែកមើលកន្លែងបន្តភ្លើង ហើយនិងដើម្បីពន្លត់ភ្លើង។ ដើម្បីឱ្យជាក់ថា ភ្លើងរលត់ អស់គ្មានសល់ ក្រសួងពន្លត់អគ្គីភ័យ អាចធ្វើដូចខាងក្រោមនេះ

១-កាត់ និង/ឬដកខ្សែកាប ធុងអាគុយដើម្បីការពារមិនឱ្យឆ្លងភ្លើង នៅកន្លែងដែលរុំកុំឱ្យ ឆ្លង ភ្លើង ឬកន្លែងតភ្លើង ត្រូវខូចខាត។

២-ដកយកពូកចេញពីកៅអីទាំងអស់ ជាពិសេសបើគេប្រើពូកសំឡី។

៣-ចូលដោយបង្ខំទៅក្នុងថតដាក់តវ៉ាន់ ខាងកន្លែងអ្នកជិះខាងមុខ កន្លែងម៉ាស៊ីនរថយន្ត ហើយនិងតួទរថយន្ត ដើម្បីពន្លត់ភ្លើង ឆែកមើលកន្លែងតភ្លើង ហើយឆែកមើលកន្លែង ចូលទៅដល់ខ្សែកាបធុងអាគុយ។

# សត្វចិញ្ចឹម

ផ្សែងអាចធ្វើឱ្យសួត ឆ្កែ ឬឆ្មា ខូចប៉ុន្មាននាទីប៉ុណ្ណោះ ហើយផ្កាភ្លើងអាចបណ្តាលឱ្យរលាកយ៉ាង ឈឺចាប់ ដែលអាចលាក់ពួននៅក្រោមរោមរបស់សត្វចិញ្ចឹម របស់លោកអ្នក។ ឆ្កែតែងតែព្រុះ ហើយ រត់ចេញយ៉ាងឆ្ងាយពីទីកន្លែងកើតហេតុអគ្គីភ័យ ហើយជាញឹកញាប់ណាស់ ខ្លាចស្នូររថយន្តពន្លត់ ភ្លើង។ ឆ្មាតែងតែពួន ពីភ្លើង ដោយទៅក្រោមតុទូ ហើយនិងបន្ទប់តូចដាក់តវ៉ាន់ ហើយតាមធម្មតា ងាយរងគ្រោះដោយសារ ហឹតផ្សែងជាងឆ្កែ។

សត្វដែលភ័យខ្លាច អាចធ្វើប្រតិកម្មដោយខាំ ឬក្រចៅ។ កាន់សត្វចិញ្ចឹមដោយប្រុងប្រយ័ត្ន ហើយ ស្ងាត់ស្ងៀម។ សត្វណាដែលជួបនឹងអគ្គីភ័យ តែងតែរុំព័ទ្ធទៅដោយផ្សែង និងម្រែងភ្លើង។ ឆ្មា តែងតែសំអាតខ្លួនវា ដោយលិត ខ្លួនវារហូតទាល់តែគ្មានក្លិនផ្សែង។ ដោយធ្វើដូច្នេះ វានឹងលេបម្រែង ភ្លើង និងសារធាតុផ្សេងៗទៀតនៃភ្លើង ដែលអាចឱ្យឆ្មាមានគ្រោះថ្នាក់។ ឆ្មា ដែលរងដោយភ្លើង គួរលោកអ្នកដុះលាងរោមវា ដោយប្រយ័ត្ន ហើយគ្របខ្លួនវា ហើយប្រើទឹកក្តៅអ៊ុនៗ និងថ្នាំកក់សក់ សំរាប់កូនង៉ា។ លោកអ្នកអាចធ្វើដូច្នេះដោយខ្លួនឯងក៏ប៉ុន្តែម្ចាស់សត្វចិញ្ចឹម ឃើញថាសត្វមិនសូវតាន តឹងពេក បើពេទ្យសត្វមានជំនាញ ឬសមាជិកបុគ្គលិកពេទ្យសត្វ ធ្វើកិច្ចការនេះវិញ។

→បញ្ជាក់ឱ្យច្បាស់ថាសត្វចិញ្ចឹមរបស់លោកអ្នកពាក់ផ្លាកសំគាល់ខ្លួន មានពិតមានទាក់ទង លោកអ្នក ផង ។ បើសត្វចិញ្ចឹមរបស់លោកអ្នក វង្វេងបាត់ក្នុងពេលជ្រួលច្របល់ ទូរស័ព្ទទៅការិយា ល័យត្រួត ពិនិត្យសត្វ របស់ស្រុកម៉ុងហ្គោម៉ឺរី ។

*ក្រោយអគ្គីភ័យមក យើងតែងតែស្នើជូនយោបល់ឱ្យលោកអ្នកយកសត្វចិញ្ចឹម ទៅឱ្យពេទ្យសត្វ របស់លោកអ្នក ពិនិត្យមើលភ្លាមដែលអាចធ្វើទៅបាន ។*

# យល់អំពីលក្ខខណ្ឌធានារ៉ាប់រង

មានលក្ខខណ្ឌធម្មតា ដែលប្រើនៅក្នុងឧស្សាហកម្មធានារ៉ាប់រង ដែលអ្នកទិញយល់ច្រឡំជាញឹកញាប់ ។ លោកអ្នកនឹងត្រូវប្រឈម នឹងទស្សនៈវិស័យអំពីតំលៃនៃផ្ទះ របស់លោកអ្នក នៅក្នុងការទូទាត់សង ការខូចខាតដោយអគ្គីភ័យ ឬនៅក្នុងការទាមទារឱ្យសងការខូចខាត ក្នុងគ្រោះថ្នាក់នៅក្នុងពន្ធដារ ប្រាក់ចំណូលសហព័ន្ធ ។ ការដឹងអំពីល័ក្ខណ្ឌខាងក្រោមនេះ នឹងជួយលោកអ្នកឱ្យយល់អំពីដំណើរការ ដែលត្រូវប្រើ ដើម្បីកំណត់តំលៃការបាត់បង់របស់លោកអ្នកក្នុងអគ្គីភ័យ ។

លោកអ្នកអាចធានារ៉ាប់រងទ្រព្យសម្បត្តិរបស់លោកអ្នក ពីរយ៉ាងៈ តាមតំលៃសាច់ប្រាក់ពិតរបស់វា ឬតំលៃវត្ថុសងជំនួស ។ សូមបញ្ជាក់ឱ្យច្បាស់ថាត្រូវពិនិត្យមើលជាមួយភ្នាក់ងាររបស់លោកអ្នក ឬតំណាងក្រុមហ៊ុន តើលក្ខខណ្ឌសំណងណាមួយល្អជាងគេសំរាប់ស្ថានការពិសេសរបស់លោកអ្នក ។

ការបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់លោកអ្នក ដោយសារអគ្គីភ័យអាចលំបាកនឹងវាស់វែង ។ ទោះ ជាយ៉ាងណាក្តីវត្ថុទាំងនោះមានតំលៃចំណងពិសេស ចំពោះលោកអ្នក ។  យ៉ាងណាមេញគឺជាការវាស់ វែងតំលៃមិនលំអៀង ដែលលោកអ្នកជាអ្នកមានការធានារ៉ាប់រង ហើយនិងសេវាប្រាក់ចំណូលក្នុង ប្រទេស Internal Revenue Service និងប្រើធ្វើជាលក្ខណៈតែមួយសំរាប់ពិភាក្សាគ្នា ។

## តំលៃនៅពេលទិញ

នេះជាចំណុចសំខាន់មួយ នៅក្នុងការសំរេចតំលៃចុងក្រោយនៃវត្ថុនោះ ។ បង្កាន់ដៃ នឹងជួយពិនិត្យ មើលបញ្ជាក់អំពីតំលៃ ។

## តំលៃយុត្តិធមិនៅផ្សារមុនអគ្គីភ័យ

គំនិតនេះក៏បញ្ជាក់ផងដែរនូវ**តំលៃសាច់ប្រាក់ពិតប្រាកដ** ។ នេះគឺជាតំលៃលោកអ្នកអាចទទួលពីវត្ថុ នោះ បើលោកអ្នកលក់វា មួយថ្ងៃមុនអគ្គីភ័យ ។ តំលៃនេះនឹង បញ្ជាក់អំពីតំលៃរបស់វា នៅពេលដែលទិញដោយដកតំលៃ ដែលគេប្រើវាហើយ តាំងពីពេលទិញមក ។

## តំលៃសាច់ប្រាក់ពិតប្រាកដ

នេះជាចំនួនប្រាក់ចាំបាច់ ដែលជួយលោកអ្នក ដែលជាអ្នកមានការធានារ៉ាប់រង យកទ្រព្យសម្បត្តិ ដែលខូចខាតមកវិញ ឱ្យបានប្រហែលដូចស្ថានភាពដើមវិញ នៅពេលដែលវា បាត់បង់ទៅ ។ នៅពេល ដែលដំណើរការជួសជុលចប់ហើយ តំលៃទ្រព្យសម្បត្តិរបស់លោកអ្នកមិនគួរឡើងថ្លៃទេ ។ នៅពេល ទទួលតំលៃជាសាច់ប្រាក់ពិតប្រាកដ លោកអ្នកមិនគួរចំណេញដោយសារការបាត់បង់ទេ ។ តំលៃជា សាច់ប្រាក់ពិតប្រាកដ លោកអ្នកមិនគួរចំណេញដោយសារការបាត់បង់ទេ ។ តំលៃជាសាច់ប្រាក់ពិត ប្រាកដត្រូវកំណត់ដោយតំលៃនៃវត្ថុថ្មី នៅពេលបាត់បង់វត្ថុចាស់ ហើយបូកបញ្ចូលកំលាំងពលកម្ម ហើយនិងគិតថ្លៃចំណាយដ៏ទៃទៀត ដកហូតចេញតំលៃចុះ ដូចជាប្រើប្រាស់ សឹករហែក ហើយនិងភាពចាស់ជិតផុលតសម័យ ដើម្បីកំណត់ស្ថានភាពមុនការបាត់បង់ទ្រព្យ សម្បត្តិនោះ ។

## ការចុះតំលៃ

ការចុះតំលៃជាពាក្យផ្លូវការប្រើដើម្បីសំដែងតំលៃដែលវត្ថុមួយដែលបាត់បង់ក្នុងមួយរយៈពេល ។

## តំលៃជាសំណងវិញ

នៅពេលដែលលោកអ្នកទិញការធានារ៉ាប់រងសំរាប់ទ្រព្យសម្បត្តិខូចខាត យោងទៅលើ តំលៃទ្រព្យសម្បត្តិថ្មីជាសំណងជំនួស ពាក្យថា តំលៃទ្រព្យសម្បត្តិថ្មីជំនួស ត្រូវជំនួសពាក្យថា តំលៃ សាច់ប្រាក់ ពិតប្រាកដ ហើយតំរូវឱ្យគិតគូរអំពីតំលៃទ្រព្យសម្បត្តិចាស់ ដោយមិនគិតអំពី ការ បាត់បង់តំលៃខ្លះ ។

## តំលៃក្រោយពីអគ្គីភ័យ

តំលៃនេះនៅពេលខ្លះ គេប្រើយោងទៅលើ តំលៃវត្ថុមិនអន្តរាយ ។

# ការយកប្រាក់ថ្មីមកដាក់ជាសំណង

**បើប័ណ្ណប្រាក់សន្សំរដ្ឋាភិបាល** (Saving Bonds )របស់លោកអ្នកត្រូវខូចខាត ឬបំផ្លាញ គេនឹង ដាក់សងប័ណ្ណនោះ ដោយមិនបាច់បង់ថ្លៃក្រោយពីដាក់ពាក្យសុំ និយាយអំពីការបាត់បង់ ។ វាសំខាន់ ណាស់ បើលោកអ្នកបានទុកបញ្ជីប័ណ្ណនោះ ដោយមានថ្ងៃខែ ដែលវាចេញ និងលេខរៀងទុក នៅ ក្នុងទី កន្លែងមានសុវត្ថិភាព ដាច់ដោយឡែកពីប័ណ្ណគ្នានោះ ។ គួរដាក់ឈ្មោះ និងអាស័យដ្ឋាននៅលើ ប័ណ្ណនោះ ថ្ងៃខែ ប៉ាន់ស្មាន ឬពេលវេលាទិញថា តំលៃនិងចំនួនប៉ាន់ស្មាននៃតំលៃ និមួយៗ ។ គួរ ដាក់ការបាត់បង់ ដោយលំអិត ព្រមជាមួយប័ណ្ណដែលខូចខាត ជាផ្នែកៗ បើវាឆេះ ឬត្រូវហែកហួរ ហើយផ្ញើទៅ:

The Bureau of the Public Debt
Department of Public Debt
Saving Bonds Operations
P.O Box 1328
Parkersburg, WV 28106-1328

ការបំពេញក្រដាសបំពេញ PDF 1048 និងជួយពន្លឿនការដាក់សងប័ណ្ណ រដ្ឋាភិបាល ក្រដាស បំពេញទាំងនោះ ជាញឹកញាប់ណាស់ ចេញពីធនាគារ ក្នុងស្រុក ឬធនាគារទុកបំរុងសហព័ន្ធ Federal Reserve Bank ឬសាខា ឬចេញពីការិយាល័យ ប្រាក់បំណុលសាធារណ: Bureau of the Public Debt ។ ប័ណ្ណរដ្ឋាភិបាលណាដែលចេញម្តងទៀត នឹងមានចុះថ្ងៃខែចេញ លើកមុន ។

កុំកាន់ប្រាក់ដែលឆេះច្រើនពេក ។ ព្យាយាមដាក់បញ្ចូលប្រាក់ក្រដាស និមួយៗឬផ្នែកខ្លះៗ នៃក្រដាស ប្រាក់ នៅក្នុងក្រដាសផ្លាស្ទិក ដើម្បីរក្សាទុក ។ បើប្រាក់ឆេះតែពាក់កណ្តាល ឬតិចជាងនេះ បើពាក់ កណ្តាល ឬជាងពាក់កណ្តាលនៅល្អ លោកអ្នកអាចយកប្រាក់នៅសល់ ហើយល្អនោះ ទៅកាន់ធនាគារ ទុកបំរុងសហព័ន្ធ នៅក្នុងស្រុកដើម្បី យកប្រាក់ថ្មីជំនួស ។ សួរបុគ្គលិកធនាគារ រកធនាគារនៅ ជិត ជាងគេ ឬលោកអ្នកអាចផ្ញើប្រាក់ឆេះ ឬរហែកតាមប្រៃសណីយ៍ដោយប្រេ registered mail, return receipt requested ទៅអាស័យដ្ឋាន:

Department of the Treasury
Bureau of Engraving and Printing
Office of Currency Standards
PO Box 37048
Washington DC 20013

ប្រាក់កាក់វៀចបាត់ទំរង់ ឬរលាយ អាចយកទៅធនាគារទុកបំរុងសហព័ន្ធ ឬផ្ញើទៅតាមប្រៃសណីយ៍ ដោយប្រើ registered mail, return receipt requested ទៅអាស័យដ្ឋានៈ

Superintendent
US Mint
PO Box 400
Philadelphia PA 19105

## ពិតមានអំពីពន្ធដារ

ពិគ្រោះជាមួយគណនេយ្យករ ទីប្រឹក្សាពន្ធដា ឬ Internal Revenue Service អំពីផលកំរៃ សំរាប់មនុស្ស ត្រូវការប្រាក់ដោយមានប្រាក់បន្តិចបន្តួច ក្រោយពីបាត់បង់ដោយសារអគ្គីភ័យ ។

## តម្រុយអំពីទ្រព្យសម្បត្តិអាចស្តារបាន

ពាណិជ្ជកម្មជាវិជ្ជាជីវៈ ខាងការខូចខាតដោយអគ្គីភ័យ និងទឹក អាចជាប្រភពល្អប្រសើរមួយ ក្នុងការ សំអាត និងស្តារឡើងវិញ នូវទ្រព្យសម្បត្តិផ្ទាល់ខ្លួន របស់លោកអ្នក ។ សួរយោបល់ក្រុមហ៊ុនធានា រ៉ាប់រងរបស់លោកអ្នក ជានិច្ចឱ្យបានទទួលការណែនាំ ហើយលោកអ្នកអាចមានលទ្ធភាព ស្តារ ទ្រព្យ សម្បត្តិឡើងវិញ ដោយប្រើពិតមាន ស្តួច ស្តើង តែសំខាន់ជាជំនួយទាំងនេះ:

## សំលៀកបំពាក់

សូមប្រុងប្រយ័ត្នមុនលោកអ្នកចាប់ផ្តើម ពិសោធន៍មើលខោអាវ មុននឹងយកវាទៅធ្វើអ្វីមួយ ហើយ ធ្វើតាមការណែនាំ ក្រុមហ៊ុនធ្វើខោអាវនោះ ។ វត្ថុរាវលាយច្រើនមុខ ជាច្រើនសំរាប់សំអាតនៅក្នុង នេះមានសារធាតុឈ្មោះ TSP ។ Tri-Sodium Phosphate ជាធាតុមួយ ដែលតាមធម្មតា គេប្រើធ្វើ ជាគ្រឿងលាងសំអាត ហើយគួរប្រើដោយប្រុងប្រយ័ត្ន ហើយទុកឱ្យឆ្ងាយពីដៃកូនក្មេង ហើយនិង សត្វចិញ្ចឹម ។ សូមពាក់ស្រោមដៃកៅស៊ូ ហើយអានផ្លាកមើលការណែនាំយ៉ាងសំខាន់ ។

## ព្រំតូចៗនិងកម្រាលព្រំ

ព្រំតូចៗ និងកម្រាលព្រំ គួរទុកឱ្យវាស្ងួត ឱ្យត្រឹមត្រូវ ។ ព្រំតូចៗ គេអាចលាងសំអាត ដោយហាល សំដិល បូមដោយម៉ាស៊ីន និងប្រើសាប៊ូទឹក ។ ព្រំតូចៗគួរហាលឱ្យស្ងួតយ៉ាងឆាប់អាចធ្វើទៅបាន ។ ឡាតវាឱ្យរាបស្មើ ហើយដាក់វាឱ្យត្រូវខ្យល់ក្តៅ ហើយស្ងួតដែលចេញចូល ។ កង្ហារបើកបក់ខ្យល់លើ ព្រំតូចៗ នឹងធ្វើឱ្យឆាប់ស្ងួត ។ គួរធ្វើឱ្យជាក់ថាព្រំតូចៗស្ងួតពិតប្រាកដ ។ ទោះបីផ្ទៃខាងក្រៅទំនងដូច ជាស្ងួតហើយក៏ដោយ

ភាពសើមនៅបាតកញ្ចុំអាចធ្វើឱ្យព្រំរលួយ យ៉ាងឆាប់រហ័ស។ ដើម្បីយក ពិតមានអំពី ការលាងសំអាត និងថែរក្សាកម្រាលព្រំ ទូរស័ព្ទទៅអ្នកលក់កម្រាលព្រំ ឬអ្នកដាក់ កម្រាលព្រំឱ្យ ឬអ្នកលាងសំអាតកម្រាលព្រំមានវិជ្ជាជីវៈ ប្រកបដោយគុណសម្បត្តិ។

## គ្រឿងធ្វើពីស្បែកនិងសៀវភៅ

យកក្រណាត់សើមជូតវត្ថុធ្វើពីស្បែក រួចហើយជូតនឹងក្រណាត់ស្ងួត។ យកកាសែតញាត់ពីក្នុងកាបូប ដៃកុំឱ្យខូចរាងវា។ បើកវ៉ាលីសចំហ។ វត្ថុធ្វើពីស្បែក គួរទុកឱ្យស្ងួតឆ្ងាយពីកំដៅ និងកំដៅថ្ងៃ។

លោកអ្នកគួរថែរក្សា សៀវភៅទទឹកភ្លាម១ ដែលអាចធ្វើទៅបាន។ វិធីល្អប្រសើរបំផុត ដើម្បីស្តារ សៀវភៅទទឹក គឺដាក់វាឱ្យកកនៅក្នុងទូទឹកកក គ្មានខ្យល់នេះ និងយកភាពសើមចេញ ដោយមិនធ្វើ ឱ្យទំព័រខូច។ បើមានការពន្យារពេល រកទូទឹកកកពិសេសនេះ សូមដាក់សៀវភៅនៅក្នុងទូទឹកកក កន្លែងកកធម្មតា ទំរាំរកទូទឹកកកគ្មានខ្យល់បាន។ អ្នកធ្វើការនៅបណ្ណាល័យអាចជាប្រភពល្អប្រសើរ មួយនៅក្នុងការរកនេះ។

## សោរនិងត្រចៀកសោរ

លោកអ្នកគួរដោះសោរ ជាពិសេសសោរដែក ហើយជូតដោយប្រើប្រេង។ បើដោះវាចេញមិនបានទេ បាញ់ប្រេងម៉ាស៊ីនតាមរន្ធរនុក ឬរន្ធសោរ ហើយមួលប្រដាប់សំរាប់កាន់មួល ឱ្យប្រេងរត់ស្មើគ្នា។ លោកអ្នកគួរលាង ហើយដាក់ប្រេងត្រចៀកសោរឱ្យសព្វ។

## ជញ្ជាំងក្តារក្រាលនិងគ្រឿងសង្ហារឹម

ដើម្បីយកម្រែងភ្លើង ពីជញ្ជាំង គ្រឿងសង្ហារឹម និងក្តារក្រាល ប្រើទឹកសាប៊ូរាវល្មម ឬទឹកសំរាប់ លាងវា ឬលាយល្បាយរាវក្នុងបញ្ជីដូចខាងក្រោមៈ

-៤ទៅ៦ ស្លាបព្រា Tri-Sodium Phospate

-ទឹកសំរាប់លាងវត្ថុក្នុងផ្ទះ១កែវ ឬថ្នាំដាក់ឱ្យស

-ទឹកអ៊ុណ្ហ១ ១ហ្គាឡុង

## សូមចាំថាត្រូវ

- ពាក់ស្រោមដៃកៅស៊ូ ពេលប្រើល្បាយរាវលាយគ្នានេះពេលលាងសំអាត ។ ធ្វើឱ្យជាក់ថា ប្រើទឹកក្តៅអ៊ុនៗ លាងជញ្ជាំង និងគ្រឿងសង្ហារឹមរបស់លោកអ្នក ហើយជូតឱ្យស្ងួតមែនទែន ក្រោយពីប្រើល្បាយរាវគ្នាហើយ ។

- លាងផ្ទៃទំហំ តូចម្តងមួយៗ ចាប់ពីក្តារក្រាលឡើងទៅលើ ។ រួចហើយលាងជញ្ជាំង ដោយ ប្រើទឹកស្អាតភ្លាម ។ គួរលាងពិដានក្រោយគេ ។

- កុំលាបថ្នាំថ្មីរហូតដល់ពេលជញ្ជាំង និងពិដានស្ងួតមែនទែន ។

ក្រដាសបិទជញ្ជាំងរបស់លោកអ្នក ក៏ប្រហែលត្រូវជួសជុលដែរ ។ ប្រើការពាណិជ្ជកម្ម ដើម្បីបិទចុង ក្រដាសឡើងវិញ ឬកន្លែងរបើក ។ ទាក់ទងនឹងអ្នកលក់ក្រដាសបិទជញ្ជាំង ឬអ្នកជំនាញ ខាង ដើរបិទក្រដាស ជញ្ជាំង ដើម្បីយកពិតមានអំពីរបៀបលាងក្រដាសនោះ ។ ក្រដាសបិទ ជញ្ជាំង ដែលអាច លាងបាន អាចធ្វើដូច្នេះបានដូចជញ្ជាំងធម្មតាដែរ ប៉ុន្តែលោក អ្នកត្រូវប្រុងប្រយ័ត្នកុំ ធ្វើ ឱ្យក្រដាសជោគ ។ ជូតពីក្រោមទៅលើ ដើម្បីជៀសវាងកុំឱ្យប្រឡាក់មានឆ្នូតវែងៗ ។

## គ្រឿងសង្ហារឹមធ្វើពីឈើ

- ជូតភក់ ធូលី និងកំទេចចេញ ។ កុំហាលតុទូ កណ្តាលថ្ងៃ ។ ឈើនឹងឡើងបោល ហើយរមួល ខូចរាងរបស់វា ។

- ដកថតចេញ ទុកវាឱ្យស្ងួតមែនទែន ដើម្បីកុំឱ្យវាស្អិត នៅពេលដែលលោកអ្នកដាក់ចូលវិញ

- យកច្រាសរឹងជ្រលក់ល្បាយរាវ សំរាប់សំអាតដុស គ្រឿងសង្ហារឹមឈើ ឬរនាំងចំរឹង ។

- ឈើទទឹក អាចពុក ហើយដុះស្លែ ហេតុដូច្នេះហើយ សូមទុកឱ្យវាស្ងួតមែនទែន ។ គួរបើកទ្វារនិងបង្អួចឱ្យមានខ្យល់ចេញចូល ។

- បើដុះផ្សិត យកក្រណាត់ជ្រលក់ក្នុងទឹកក្តៅ លាយជាមួយ borax ហើយជូតវា ។ ដើម្បី យកស្នាមអុចៗ មូលសៗ ឬស្នាមក្រាំងពីលើចេញ ជូតផ្ទៃឈើជាមួយក្រណាត់ជ្រលក់ ក្នុងល្បាយរាវ លាយជាមួយ អាម៉ូញ៉ាកន្លះកែវ សំរាប់ប្រើដុសលាងក្នុងផ្ទះ ធម្មតាជាមួយទឹកកន្លះពែង ។ រួចហើយ ជូតផ្ទៃឈើឱ្យស្ងួត ហើយដុសខាត់ជាមួយក្រមួន ឬជូតផ្ទៃឈើជាមួយ ក្រណាត់ជ្រលក់ក្នុងល្បាយរាវ លាយ turpentine កន្លះពែង និងប្រេង linseed oil កន្លះពែង ។ សូមប្រយ័ត្ន ពីព្រោះ turpentine អាចឆេះបាន ។

- លោកអ្នកអាចជូតឈើ ដោយប្រើជាជាតិដែលឆេះ ជ្រលក់ក្នុងក្រមួន រាវសំរាប់ដុសខាត់ ហើយសំអាតផ្ទៃនោះជាមួយ ក្រណាត់ទន់រួចហើយខាត់ឱ្យរលោង ។

## ចុះចំណែកឯវត្ថុឆាប់ខូច?

សូមកុំបរិភោគម្ហូបអាហារ ភេសជ្ជៈ ហើយនិង ឬថ្នាំដែលត្រូវកំដៅ ឬផ្សែង ។ បើសម្ភារៈទាំងនោះ ទុកនៅក្នុងកំប៉ុងបិទជិត ឬផ្សារជិត ឬនៅក្នុងទូទឹកកក ឬទូកក លោកអ្នកអាចទុកវត្ថុនោះបាន ។ សួរយោបល់អ្នកតំណាងសុខាភិបាល ក្នុងស្រុកសុំការណែនាំ របស់គេឱ្យជាក់លាក់ ហើយនិងអនុសាសន៍ ស្នើឱ្យយោបល់ទាក់ទងនឹង ការទទួលទានម្ហូប ដែលទំនងជាគ្មានគ្រោះថ្នាក់ ។ វាជាការល្អ ដែលលោក អ្នកយកម្ហូបថ្មីមកជំនួសវិញ ជាជាងធ្វើឱ្យសុខភាព របស់លោកអ្នកមានគ្រោះថ្នាក់ ដោយប្រថុយ ប្រថាន ។

## រូបថត

ការរក្សាទុករូបថត ដែលខូចជាការសំខាន់ណាស់ចំពោះអ្នករងគ្រោះដោយសារអគ្គីភ័យ ទឹកជំនន់ និងមហន្តរាយដ៏ទៃទៀត ។ បើការខូចខាតមិនធ្ងន់ធ្ងរពេកទេ លោកអ្នកប្រហែលអាចស្តារវាវិញដោយខ្លួនឯង ។ លោកអ្នកអាចថតរូបថតម្តងមួយៗ ឡើងវិញ ឬឱ្យគេថតវាតាមរបៀប digital ។ ធ្វើឱ្យជាក់ថា រូបថតត្រូវថតឡើងវិញ តាមម៉ាសីនដែលប្រើ resolution ខ្ពស់ដូចជា ៣00 dpi ដើម្បីឱ្យលោកអ្នកផ្តិតរូបថតមានគុណភាពខ្ពស់បានដែរ ។ ការថតរូបថតតាម ម៉ាស៊ីន ស្កេន ដោយប្រើ resolution ខ្ពស់ ឬចំនួនចំណុចរូបថតក្នុងមួយ inch នឹងជួយលោកអ្នក ដែលស្តាររូបថតនោះ ដោយមានការងាយស្រួល នឹងស្តាររូបថតនោះ ។ ជាញឹកញាប់ណាស់ គេអាចស្តាររូបថតបាន ដោយប្រើបច្ចេកវិជ្ជាបច្ចុប្បន្ន និងជំនាញការរបស់អ្នកមានវិជ្ជាជីវៈខាងស្តាររូបថត ។ សូមកុំឱ្យព្យាយាមបករូបថតស្អិតជាប់គ្នាឱ្យដាច់ពីគ្នា ។ បើកមើលក្នុងសៀវភៅរាយឈ្មោះ និងអាស័យដ្ឋាន yellow page ដើម្បីរកអ្នកស្តាររូបថត សួរពិតមានបន្ថែមទៀត ។

# ប្រតិបត្តិការរបស់ក្រសួងពន្លត់អគ្គីភ័យ

## សំនួរធម្មតាៈ

**សំនួរៈ ហេតុអ្វីបានជាបង្អួចត្រូវបំបែក ឬត្រូវកាត់ប្រហោងក្នុងដំបូល?**

នៅពេលដែលភ្លើងឆេះ អណ្តាតភ្លើងឆាប ឡើងទៅលើ ហើយចេញទៅក្រោយ ។ ការបំបែកកញ្ចក់ បង្អួច និង/ឬកាត់ប្រហោងដំបូលផ្ទះ ហៅថា ការធ្វើឱ្យការធ្វើអោយមានខ្យល់ចេញចូលធ្វើអោយ ចលនាភ្លើងរាលដាលទៅក្រៅនាំអោយខូចខាត ទៅជាមានដំណើរយឺត ជួយធ្វើឱ្យផ្សែងស្ទើរខ្វាក់ ភ្នែក រំសាយជាផ្សែងដែលបំបាំងភ្លើងឆេះ មែនតែន ហើយជួយឱ្យអ្នកលត់ភ្លើង អាចលត់ភ្លើងបាន ដោយមានប្រសិទ្ធិភាពជាង ។ លទ្ធផលនៃការធ្វើដូច្នេះ ធ្វើឱ្យខូចខាតទម្រង់ផ្ទះតិចជាងសំរាប់រយៈ ពេលយូរ ។

**សំនួរៈ ហេតុអ្វីបានជាគេចោះប្រហោងនៅជញ្ជាំង?**

គេធ្វើដូច្នេះដើម្បីឱ្យក្រសួងពន្លត់អគ្គីភ័យ ដឹងជាក់ច្បាស់ថា ភ្លើងរលត់អស់រលីងហើយ ហើយគ្មានភ្លើងឆេះ នៅខាងក្នុងជញ្ជាំង ឬទីកន្លែងពាក់ពួនឯណាទៀតទេ ។

**សំនួរៈ តើយើងអាចមានលទ្ធភាពទទួលយកច្បាប់ចម្លង របាយការណ៍អគ្គីភ័យដែរឬទេ?**

ដើម្បីទទួលពិតមានពីរបាយការឧប្បត្តិហេតុ សេវាគ្រាអាសន្នពេទ្យ របស់អ្នកជម្ងឺ ឬហៅថា Emergency Medical Services Incident Patient Report ឬ Fire Incident Report
លោកអ្នកត្រូវតែធ្វើសំណើររបស់លោកអ្នកទៅអាស័យដ្ឋានៈ

Montgomery County Fire and Rescue Services
Office of Quality Assurance
100 Maryland Ave Room 220
Rockville MD 20850
Questions: 240 777 2418

សូមផ្ញើភ្ជាប់ទៅជាមួយនូវវត្ថុៈ

១- ស្រេមសំបុត្រខ្នាតសំរាប់ពាណិជ្ជកម្ម មានបិទតែម អាស័យដ្ឋានរបស់លោកអ្នក

២- ថ្ងៃខែដែលអ្នកជំងឺត្រូវដឹកជញ្ជូនទៅ

៣-ពេលវេលាប៉ាន់ស្មានដែលអ្នកជំងឺត្រូវដឹកជញ្ជូនទៅ

៤-ឈ្មោះ និងនាមត្រកូលរបស់អ្នកជំងឺ

៥-ទីកន្លែងកើតហេតុ ឬអាស័យដ្ឋានដែលអ្នកជំងឺត្រូវគេដឹកនាំចេញទៅ

៦-ប្រភេទនៃឧប្បត្តិហេតុនោះ និង/ឬរបួស ដូចជា រថយន្តបុកគ្នា គាំងបេះដូង ជាដើម

៧-ការចុះហត្ថលេខា របស់អ្នកជំងឺនៅលើឯកសារស្នើថាគេគួរបញ្ចេញពតិមានរបស់ អ្នកជំងឺរូបនេះអោយគេដឹង ជាការកំណត់ថា អ្នកណា ឬមនុស្សច្រើននាក់មានច្បាប់ទទួលពតិមាន នោះ ។

៨-បើបុគ្គលដែលធ្វើសំណើនេះមិនមែនជាអ្នកជំងឺទេនោះ គេគួរដាក់ថាតើបុគ្គលនេះត្រូវជាអ្វីនឹងអ្នកជំងឺនេះផង ។ បើអ្នកជំងឺមិនអាចមានលទ្ធភាពបំពេញសំណើនោះបានទេ អ្នកតំណាងទទួលការអនុញ្ញាត្តិស្របច្បាប់របស់អ្នកជំងឺត្រូវតែផ្តល់ក្រដាសយល់ព្រម ដោយមានចុះ ហត្ថលេខាឈ្មោះសំរាប់ឱ្យបញ្ចេញពិតមាន ដោយមានការផ្តល់ឯកសារ បង្ហាញនូវអំណាច របស់ បុគ្គលនេះក្នុងការចុះហត្ថលេខា ឈ្មោះតាងនាមរបស់អ្នកជំងឺ ។ ដើម្បីស្នើការបញ្ចេញ ពិតមាននេះអ្នកតំណាងស្របច្បាប់របស់អ្នកជំងឺ ឬអ្នកតំណាងក្រុមហ៊ុនធានារ៉ាប់រង ក៏ត្រូវ ផ្តល់ការយល់ព្រមដូច្នេះដែរ ។

គេនឹងផ្ញើពិតមានទៅជូនលោកអ្នកក្នុងរយៈពេល៣០ថ្ងៃ ក្រោយពេលបានទទួលសេចក្តីស្នើ ដែលគេទទួលយកបានដែលស្របទៅតាមសេចក្តីតម្រូវ ដូចបានបញ្ជាក់ពីខាងលើស្រាប់ ។

# ការយកឯកសារ និងបញ្ជីរាយឈ្មោះមានតំលៃថ្មីមកដាក់ជំនួស

ខាងក្រោមនេះគឺជាបញ្ជីរាយឈ្មោះ ឯកសារដែលលោកអ្នកត្រូវការដាក់ជំនួស បើវាត្រូវខូចអន្តរាយ និងអ្នកដែលត្រូវទាក់ទងយកពិតមាន អំពីដំណើរការយកមកជំនួសៈ

| **ITEM**<br>**បញ្ជីរាយមុខរបស់** | **WHO TO CONTACT**<br>**អ្នកដែលត្រូវទាក់ទង** |
|---|---|
| បញ្ជីចុះឈ្មោះសត្វ<br>Animal registration papers | សង្គមស៊ីវិល<br>Humane Society |
| សៀវភៅធនាគារ (ឆែក  ប័ណ្ណសន្សំ ជាដើម)<br>Bank books (checking, savings, etc.) | ធនាគាររបស់លោកអ្នក  ជាបន្ទាន់តាមការដែលអាចធ្វើបាន<br>Your bank,  as soon as possible |
| សំបុត្រកំណើត  សំបុត្រមរណៈភាព សំបុត្រអាពាហ៏ពិពាហ៏<br>Birth, death and marriage certificates | ការិយាល័យឯកសារកត់ត្រាក្នុងរដ្ឋ ដែលលោករស់នៅ<br>Bureau of Records in the appropriate State |
| លិខិតបញ្ជាក់សញ្ជាតិ<br>Citizenship Papers | ផ្នែកអន្តោប្រវេសន៏ និង ចូលសញ្ជាតិ នៃសហរដ្ឋអាមេរិក<br>U.S. Immigration and Naturalization Services |
| ប័ណ្ណឥណទាន<br>Credit Cards | ក្រុមហ៊ុនផ្តល់បណ្ណ័  ជាបន្ទាន់តាមការដែលអាចធ្វើបាន<br>The Issuing Companies as soon as possible |
| លិខិតលែងលះ<br>Divorce Papers | តុលាការមណ្ឌល  ដែលចេញក្រឹត្យអោយ<br>Circuit Court where decree was issued |
| ប័ណ្ណបើកបរ<br>Driver’s License | ក្រសួងត្រួតពិនិត្យយានយន្ត<br>Department of Motor Vehicles |
| លិខិតបញ្ជាក់ពន្ធដារលើប្រាក់ចំណូល<br>Income Tax Records | មជ្ឈមណ្ឌល  IRS ដែលលោកអ្នកដាក់ពាក្យស្នើសុំ រឺ គណនេយ្យកររបស់លោកអ្នក<br>The IRS Center where filed or your accountant |

| | |
|---|---|
| កម្មវិធីធានារ៉ាប់រង<br>Insurance policies | ភ្នាក់ងារធានារ៉ាប់រង របស់លោកអ្នក<br>Your insurance agent |
| ឯកសារពេទ្យ<br>Medical Records | វេជ្ជបណ្ឌិតរបស់លោកអ្នក<br>Your doctor |
| លិខិតឈប់ពីយោធា<br>Military discharge papers | ក្រសួងកិច្ចការអតីតយុទ្ធជន<br>Department of Veteran Affairs |
| លិខិតខ្ចីលុយទិញផ្ទះ<br>Mortgage Papers | គ្រឹះស្ថានអោយខ្ចីលុយ<br>Lending institution |
| លិខិតឆ្លងដែន<br>Passports | កន្លែងធ្វើលិខិតឆ្លងដែន<br>Passport service |
| ប័ណ្ណភាគហ៊ុន និង ប័ណ្ណរដ្ឋាភិបាល<br>Stocks and Bonds | ក្រុមហ៊ុនដែលចេញប័ណ្ណអោយ រឺជើងសារជំនួញរបស់លោកអ្នក<br>Issuing company or your broker |
| បណ្ណ័សន្តិសុខសង្គម  រឺ ប័ណ្ណសុខភាព<br>Social Security or MedicareCards | ការិយាល័យផ្នែកលេខសន្តិសុខសង្គមប្រចាំតំបន់លោកអ្នក<br>Local Social Security Office |
| ប័ណ្ណភាគហ៊ុន និង ប័ណ្ណរដ្ឋាភិបាល<br>Stocks and Bonds | មេធាវីរបស់លោកអ្នក<br>Your lawyer |
| លិខិតកម្មសិទ្ធិ<br>Title to deeds | ក្រសួងថែរក្សារឯកសារអំពីទីតាំង  ដែលទ្រព្យសម្បត្តិស្ថិតនៅ<br>Record Department of the locality in which the property is located |
| ការធានា<br>Warranties | ក្រុមហ៊ុនផ្តល់ការធានា<br>Issuing company |
| បណ្តាំមរតក<br>Wills | មេធាវីរបស់លោកអ្នក<br>Your lawyer |
| ការធានា<br>Warranties | ក្រុមហ៊ុនផ្តល់ការធានា<br>Issuing company |

# ការធានារ៉ាប់រងរបស់អ្នកជួល

## តើការធានារ៉ាប់រងរបស់អ្នកជួលជាអ្វី?

ចំពោះអ្នកដែលជួលផ្ទះ ការធានារ៉ាប់រងរបស់អ្នកជួលផ្ទះ គឺការសងការខូចខាត ឬការបាត់បង់ទ្រព្យ សម្បត្តិផ្ទាល់ខ្លួនរបស់លោកអ្នក។ ទោះបីជាលោកអ្នកជួលពីអ្នកមានផ្ទះក៏ដោយ ក៏អ្នកចាត់ចែងការ ទ្រព្យសម្បត្តិ ឬសកលវិទ្យាល័យក្នុងនាមជានិស្សិត រស់នៅ។សយនដ្ឋានក៏ដោយ លោកអ្នកគួរ ពិចារណាអំពីការទិញធានារ៉ាប់រងរបស់អ្នកជួលផ្ទះរបស់គេ។

## ហេតុអ្វីបានជាទិញប័ណ្ណធានារ៉ាប់រងរបស់អ្នកជួលផ្ទះរបស់គេ?

*កម្មវិធីធានារ៉ាប់រងរបស់ម្ចាស់ផ្ទះលោកអ្នកមិនសងលោកអ្នកទេ*

ការយល់ច្រឡំពីបណ្តា អ្នកជួលផ្ទះ របស់គេ គឺថាការធានារ៉ាប់រង របស់ម្ចាស់ផ្ទះ របស់គេ នឹងចេញ ប្រាក់សងគេ។ ទោះបីជាម្ចាស់ផ្ទះពិតជាមាន កម្មវិធីធានារ៉ាប់រងក៏ដោយ ក៏ប៉ុន្តែកម្មវិធីទាំងនោះ ធានារ៉ាប់រងអាគារទល់នឹងការខូចខាតបណ្តាលមកពីឧប្បត្តិហេតុ ដូចជា អគ្គីភ័យ ព្រិល និងការ បំផ្លាញទ្រព្យសម្បត្តិរបស់ឯកជន ឬសាធារណៈ។ ក៏ប៉ុន្តែកម្មវិធីធានារ៉ាប់រងរបស់គេ <u>មិនសង</u> ទ្រព្យ សម្បត្តិផ្ទាល់ខ្លួន នៅក្នុងផ្ទះបន្ទប់របស់លោកអ្នកទេ។

លើកទីមួយ ដែលមនុស្សភាគច្រើនគិតអំពីការធានារ៉ាប់រង គឺការធានា រ៉ាប់រងរថយន្ត ឬផ្ទះ។ តាម ធម្មតានេះគឺដោយសារច្បាប់ ឬធនាគារតម្រូវឱ្យធ្វើដូច្នេះ។ ទោះបីជាការធានារ៉ាប់រង របស់អ្នកជួល ផ្ទះរបស់គេនៅគេមិនតម្រូវឱ្យទិញទេក៏ដោយ វាក៏ជាកម្មវិធីមួយដែល គួរមានដែរ។ កម្មវិធីនេះមិនត្រឹមតែការពារវត្ថុផ្ទាល់ខ្លួនរបស់លោកអ្នកប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏នឹងជួយលោកអ្នកឱ្យជ្រកនៅក្នុង ផ្ទះជាបណ្តោះ និងការពារទប់ទល់នឹងដំណើរត្រូវទទួលសង ដូចជាមុខចំណាយផ្នែកពេទ្យ សំរាប់ មនុស្ស រស់នៅក្នុងផ្ទះរបស់លោកអ្នក ឬមេធាវី បើលោកអ្នកត្រូវនរណាម្នាក់ប្តឹង ដែលរបួស ដោយ អចេតនានៅក្នុងផ្ទះ ឬលើដីរបស់លោកអ្នក។ ក្រោយពីពេល ដែលលោកអ្នកកំណត់ សេចក្តីត្រូវការ ទិញប័ណ្ណធានារ៉ាប់រង របស់អ្នកជួលផ្ទះ របស់គេហើយ ការដឹងអំពីការ យកជម្រើសណាមួយ នឹងជួយ លោកអ្នកឱ្យជ្រើសរើសយកកម្មវិធីល្អ ជាងគេបំផុត។

*ប័ណ្ណធានារ៉ាប់រងរបស់អ្នកជួលផ្ទះរបស់គេនៅ ការពារលោកអ្នកពី មហន្តរាយ*

បើដំបូលផ្ទះនៅក្នុងផ្ទះ ដែលលោកអ្នកជួលគេ ត្រូវខូចខាត ដោយខ្យល់ ឬព្រឹលក្នុងខ្យល់ព្យុះ ពិត ណាស់ហើយ ម្ចាស់ផ្ទះរបស់លោកអ្នកចេញសងតម្លៃដំបូលនោះ ។ ចុះចំពោះម៉ាស៊ីនកំព្យូទ័រថ្មី ស្រឡាងរបស់លោកអ្នក និងទូរទស្សន៍ថ្មី ដែលត្រូវខូចខាតនោះ? ម្យាងវិញទៀត នៅពេលដែល ដំបូលផ្ទះត្រូវជួសជុល តើលោកអ្នកមានប្រាក់កាសគ្រប់គ្រាន់ដើម្បីរកទីកន្លែងមួយផ្សេងទៀតរស់ នៅបានដែរ ឬទេ? ទាំងនេះហើយ ជាវត្ថុដែលកម្មវិធីធានារ៉ាប់រង របស់អ្នកជួលផ្ទះរបស់គេនៅត្រូវ ចេញសង ។ ព្រមជាមួយការសងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងមុខចំណាយរស់នៅ កម្មវិធីរបស់លោក អ្នកក៏ចេញសងផងដែរ នូវការទទួលខុសត្រូវរបស់លោកអ្នកចំពោះអ្វីមួយ ឬការខូចខាត ដែលលោក អ្នកបានធ្វើឱ្យមានចំពោះ អ្នកដ៏ទៃ ឬទ្រព្យសម្បត្តិរបស់គេ ។

ឥឡូវនេះ ដែលលោកអ្នកបានសំរេចចិត្តថា ការធានារ៉ាប់រប របស់អ្នកជួលផ្ទះរបស់គេនៅ ជាកម្មវិធី ល្អសំរាប់លោកអ្នកហើយ មានអ្វីដែលលោកអ្នកត្រូវពិចារណាមើល នៅពេលទិញកម្មវិធីសំរាប់ លោកអ្នក ដែលនឹងមានផលប៉ះពាល់ ទៅលើតម្លៃ និងការសង ។

១- ចំនួនប្រាក់ដុល្លា ក្នុងការសង: នេះជាកត្តានាំមុខគេ នៅក្នុងតម្លៃ និងការសង ។ ចំនួនប្រាក់ដុល្លា-គេមិនដាក់ទៅលើទ្រព្យសម្បត្តិនិមួយៗទេ ។ ផ្ទុយទៅវិញ ចំនួនមិនប្រែប្រួល សំរាប់ទ្រព្យសម្បត្តិរបស់លោកអ្នកទាំងអស់ ត្រូវគេកំណត់ធ្វើ ។ ពិតណាស់ហើយ បើលោកអ្នកទិញកម្មវិធីសង មានចំនួនសងច្រើន នោះកម្មវិធីធានារ៉ាប់រងក៏មានតម្លៃថ្លៃ ជាងដែរ ។

២- ការបង់ប្រាក់នៅពេលកើតមហន្តរាយៈ ចំនួនប្រាក់ នេះទំនងជាកត្តានាំមុខគេ ក្នុងការពិចារណា មើលមុខចំណាយ និងចំនួនប្រាក់ ដែលលោកអ្នកចង់ចេញប្រាក់ពីហោប៉ៅ មុនក្រុមហ៊ុនធានារ៉ាប់រង ចាប់សងលោកអ្នក ។ ការសងនេះ ដែលលោកអ្នកត្រូវចេញសងមុនខ្លះៗ មុនក្រុមហ៊ុនចេញសងចំនួននៅ សល់តាមក្រោយ គឺសងចំនួនសងនេះ លើកលែងតែចំនួនទទួលខុសត្រូវ (liability)។

៣- តម្លៃសាច់ប្រាក់មែនទែន ឬ ACV ឬតម្លៃដាក់សងជំនួស នៅពេលដែលបុគ្គលិក ក្រុមហ៊ុនធានារ៉ាប់រង ទៅផ្ទះរបស់លោកអ្នក ដើម្បីសងប្រាក់លោកអ្នកសំរាប់ម៉ាស៊ីន កុំព្យូទ័រ និងទូរទស្សន៍ ប្រាក់ដែលជូនលោកអ្នក គឺគិតទៅតាមកត្តាទាំងនេះ ។ កម្មវិធី ធានារ៉ាប់រង ជាមូលដ្ឋាននឹងសងតម្លៃ សាច់ប្រាក់មែនទែន ដែលជាតម្លៃទ្រព្យសម្បត្តិ នៅពេលដែលត្រូវខូចខាត ។ ក៏ប៉ុន្តែ បើលោកអ្នកជ្រើសរើសយកតម្លៃដាក់សង ជំនួសវិញ លោកអ្នកនឹងទទួលដាក់សងជំនួស ។ ឧទាហរណ៍ ដូចជា គេនឹងសង ទូរទស្សន៍អាយុ៥ឆ្នាំ របស់លោកអ្នកជាចំនួនប្រាក់ស្មើគ្នា

និងតម្លៃដែលលោកអ្នក ត្រូវបង់បើលោកអ្នកទិញ ទូរទស្សន៍ ដូចគ្នាហើយថ្មី ។ វត្ថុថ្លៃ ដែលចោរតែងតែលួច ដូចជាគ្រឿងអលង្ការ និងកាំភ្លើង គេសងមានកំរិត ដូច្នេះ ជាការល្អបើលោកអ្នកដាក់ វា ក្នុងកម្មវិធីដាច់ចោយឡែក ។ ទម្លៃដាក់សងជំនួស គួរណាស់តែយកដោយលោក អ្នក បង់លើសបន្តិចបន្តួចប៉ុណ្ណោះ ទៅលើកម្មវិធីនេះ ។

៤- ទីកន្លែង និងការទាមទារឱ្យសងកាលពីលើកមុន បើលោកអ្នកជួលផ្ទះនៅក្នុងកន្លែង ដែលចោរចូលចិត្តទៅលួច លោកអ្នកប្រហែលជាត្រូវបង់ប្រាក់ច្រើនជាង ដើម្បីទិញ ប័ណ្ណធានារ៉ាប់រង ហើយបើលោកអ្នក ឬមនុស្សនៅមុនលោកអ្នក ឬអ្នកជិតខាងធ្លាប់បាន ទាមទារឱ្យសងក្នុងចំនួនច្រើន នេះទំនងជាអាចមានផលប៉ះពាល់ទៅលើ តម្លៃ ត្រូវបង់ទិញប័ណ្ណធានារ៉ាប់រង ។

ទោះបីលោកអ្នកគិតថា ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់លោកអ្នក គ្មានតម្លៃល្មមគ្រប់គ្រាន់ឱ្យធានា រ៉ាប់រងទេក៏ដោយ ក៏តម្លៃនៃកម្មវិធីសងក្នុងការទទួលខុសត្រូវ (liability) គឺគួរតែបង់សំរាប់ប័ណ្ណធានារ៉ាប់រងរបស់ អ្នកជួលផ្ទះរបស់គេនៅដែរ ។

*ការមានប័ណ្ណធានារ៉ាប់រង សំរាប់អ្នកជួលផ្ទះ ជួយឱ្យលោកអ្នក អាចទិញប័ណ្ណធានារ៉ាប់រង សំរាប់ម្ចាស់ផ្ទះ នៅពេលអនាគត*

ការធានារ៉ាប់រងសំរាប់អ្នកជួលផ្ទះរបស់គេនៅជួយលោកអ្នកបង្កើតប្រវត្តិទាក់ទងជាមួយក្រុមហ៊ុន ធានារ៉ាប់រង ។ បើលោកអ្នកមានគំរោងចង់ទិញផ្ទះ ការមានធានារ៉ាប់រងសំរាប់អ្នកជួលផ្ទះគេ នៅ អាចជួយឱ្យលោកអ្នកងាយស្រួលទិញកម្មវិធីធានារ៉ាប់រង សំរាប់អ្នកមានផ្ទះ ហើយអាចជួយឱ្យ លោកអ្នកទិញបានធូរថ្លៃផង ។

## <u>តើការធានារ៉ាប់រងសំរាប់អ្នកជួលផ្ទះថ្លៃប៉ុន្មាន?</u>

គួរឱ្យឆ្ងល់ដែរ កម្មវិធីធានារ៉ាប់រង ជាមូលដ្ឋានសំរាប់អ្នកជួលផ្ទះគេ នៅតាមធម្មតាតិចជាង ២០០ ដុល្លា ក្នុងមួយឆ្នាំ ។ អ្នកជួលផ្ទះគេ ដែលមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនមានតម្លៃរាប់ម៉ឺន ឬរាប់សែនដុល្លា ឬដែលត្រូវការកម្មវិធីសងក្នុងការទទួលខុសត្រូវធំ នឹងត្រូវបង់ថ្លៃច្រើនទៀត ។ ការវាយតម្លៃរបស់ លោកអ្នកផ្ទាល់ នឹងសំរេចនៅលើកត្តាមួយចំនួន មានរួមទាំងប្រវត្តិធានារ៉ាប់រង ពីអតីតកាល របស់ លោកអ្នក និងទីកន្លែងដែលលោកអ្នករស់នៅ ។ យោងទៅតាមសមាគមន៍ជាតិ នៃអធិការបតីធានា រ៉ាប់រង(National Association of Insurance Commissioners) ប្រាក់បង់ ជាមធ្យមភាគឱ្យ ក្រុមហ៊ុនធានារ៉ាប់រង

នៅទូទាំងប្រទេស សំរាប់អ្នកជួលផ្ទះ នៅក្នុងឆ្នាំ២០០០ គឺ ១៧៥ដុល្លា សំរាប់ កម្មវិធីធានារ៉ាប់រង១ឆ្នាំ ក៏ប៉ុន្តែប្រាក់នេះផ្លាស់ប្តូរជាច្រើន យោងទៅតាមរដ្ឋ។ ទោះបីតម្លៃបង់ថោក ហើយផលប្រយោជន៍ទទួលច្រើនក៏ដោយ ការស្ទង់មតិនៅឆ្នាំ ២០០៣ របស់ក្រុមហ៊ុនឈ្មោះភ្នាក់ងារ និងជើងសារជំនួញធានារ៉ាប់រងឯករាជ្យ នៃ សហរដ្ឋអាមេរិក (Independent Insurance Agent and Brokers of America) រកឃើញថា អ្នកឆ្លើយការស្ទង់មតិ ៦៤% ដែលរស់នៅក្នុងផ្ទះជួល គ្មានការធានារ៉ាប់រង សំរាប់អ្នកជួលផ្ទះទេ។

### *តើខ្ញុំត្រូវដឹងអំពីអ្វីខ្លះទៀត?*

ជាបន្ថែមទៀត គួរគិតគូរអំពីរឿង ខាងក្រោមនេះ ដើម្បីធានាឱ្យជាក់ច្បាស់ថា លោកអ្នកជ្រើសរើស ទិញកម្មវិធីធានារ៉ាប់រង សំរាប់អ្នកជួលផ្ទះគេនៅ ដែលត្រឹមត្រូវសំរាប់លោកអ្នក។ ជាដំបូងកម្មវិធី ធានារ៉ាប់រងទាំងអស់មានចំនួន ប្រាក់លោកអ្នក ត្រូវបង់មុន មុននឹងក្រុមហ៊ុនធានារ៉ាប់រងចេញសង ទាំងអស់នៅសល់ពីនេះ។ បើប្រាក់សងមុននេះមានចំនួនកាន់តែតិចឡើង ចំនួនបង់ការធានារ៉ាប់រង ក៏ កាន់តែថ្លៃដែរ។ នៅពេលដែលលោកអ្នក អាចបញ្ចុះប្រាក់បង់ទិញ ការធានារ៉ាប់រង ដោយ តម្លើង ប្រាក់ បង់មុនលោកអ្នកបញ្ជាក់ឱ្យច្បាស់ថា លោកអ្នកអាចបង់ប្រាក់សងមុននេះបានដែរ បើ មហន្តរាយកើតឡើង។ ទីពីរ កម្មវិធីធានារ៉ាប់រងមានការបដិសេធន៍ ដែលលោកអ្នកត្រូវជ្រាប។ តាមធម្មតា កម្មវិធីធានារ៉ាប់រងជាមូលដ្ឋាន មិនធានារ៉ាប់រងមហន្តរាយធម្មជាតិ ជូនលោកអ្នកទេ ដូច ជា ទឹកជំនន់ និងការរញ្ជួយព្រះធរណី ជាដើម ឬការបាត់បង់វត្ថុខ្លះដូចជា គ្រឿងអលង្ការ ឬវត្ថុ សិល្បៈ។ ក៏ប៉ុន្តែលោកអ្នកអាចទិញកម្មវិធីធានារ៉ាប់រង បន្ថែមលើនេះ ដើម្បីធានារ៉ាប់រងការបាត់បង់ ទាំងនោះដែលមានលទ្ធភាព អាចកើតមានបាន។

### *តើខ្ញុំទិញប័ណ្ណធានារ៉ាប់រងសំរាប់អ្នកជួលផ្ទះដោយរបៀបណា?*

ការទិញប័ណ្ណធានារ៉ាប់រង សំរាប់អ្នកជួលផ្ទះគេ នៅជាការស្រួលទេ។ លោកអ្នក អាចយកការដាក់តម្លៃ ហើយទិញការធានារ៉ាប់រងនោះ តាមប្រព័ន្ធអ៊ិនធើណិត ឬលោកអ្នកអាចទិញការធានារ៉ាប់រង ក្នុងស្រុក។ អ្នកលក់ការធានារ៉ាប់រង ខ្លះលក់ចុះថ្លៃឱ្យមនុស្សណា ដែលមានប័ណ្ណធានារ៉ាប់រងរថយន្ត របស់គេ រួចហើយឆែកមើល ក្រែងលោ ការធានារ៉ាប់រងរថយន្ត របស់លោកអ្នក អាចចុះថ្លៃដូច្នេះ ដែរ។

# ក្រោយពីភ្លើងឆេះ

បញ្ជីរាយកិច្ចការគូសគំនូសខាងក្រោមនេះធ្វើជាការយកធ្វើជាឧទាហរណ៍ងាយស្រួលនជាការណែនាំសំរាប់លោកអ្នកឆែកមើលភ្លាមៗ ក្រោយពីអគ្គីភ័យកើតមានៈ

☑ ទាក់ទងនឹងសេវាសង្គ្រោះមហន្តរាយក្នុងតំបន់ដូចជាអង្គការកាកបាទក្រហម បើលោកអ្នកត្រូវការទីជំរកផ្ទះបណ្តោះអាសន្ន ម្ហូបអាហារ និងថ្នាំពេទ្យ ។

☑ បើលោកអ្នកមានការធានារ៉ាប់រង ទាក់ទងនឹងក្រុមហ៊ុនធានារ៉ាប់រង របស់លោកអ្នកភ្លាមសុំយកការពន្យល់លំអិតអំពីការការពារ ទ្រព្យសម្បត្តិ ការធ្វើបញ្ជីសារពើភ័ណ្ឌ និងការទាក់ទង នឹង ក្រុមហ៊ុនស្តារការខូចខាត ពីអគ្គីភ័យឡើងវិញ ។ បើលោកអ្នកគ្មានការធានារ៉ាប់រងទេ ព្យាយាមទាក់ទងនឹងអង្គការឯកជនសុំជំនួយ ។

☑ សួរក្រសួងអគ្គីភ័យ ដើម្បីបញ្ជាក់ឱ្យច្បាស់ថា ទីលំនៅរបស់លោកអ្នក មានសុវត្ថិភាពហើយមុននឹងចូលទៅ ។ ប្រយ័ត្នរកមើលរចនាសម្ព័ន្ធ ដែលខូចខាត ដោយអគ្គីភ័យ ។

☑ ក្រសួងអគ្គីភ័យគួររកមើលថាតើ ប្រព័ន្ធទឹកភ្លើង ឧស្ម័នប្រើបាន ដោយគ្មានគ្រោះថ្នាក់ ឬគេបានដកខ្សែភ្លើងចេញ មុនគេចេញពីទីកន្លែងនោះទៅ ។ សូមកុំ ព្យាយាមដោតខ្សែភ្លើងវិញ ដោយខ្លួន ឯង ។

☑ ឆែកមើលទ្រព្យសម្បត្តិ និងវត្ថុខូចខាតមានរាយក្នុងបញ្ជីរាយវត្ថុ គូសគំនូស ។ កុំបោះចោល វត្ថុណាដែលខូចខាត រហូតទៅដល់ពេលធ្វើបញ្ជីរាយវត្ថុ រួចហើយ ។

☑ ព្យាយាមរកឱ្យឃើញ នូវឯកសារនិងកំណត់មានតម្លៃ ។ យោងទៅតាមពិតមានអំពី អ្នកត្រូវទាក់ទងជាមួយ និងដំណើរការដាក់វត្ថុជំនួសដែលមានជូន នៅក្នុងឯកសារនេះស្រាប់ ។

☑ បើលោកអ្នកចេញពីផ្ទះ របស់លោកអ្នកហើយ ទាក់ទងនឹង ក្រសួងនគរបាលក្នុងស្រុក ដើម្បីជំរាប់ឱ្យគេដឹងថា ទីកន្លែងនោះគ្មានមនុស្សនៅទេ ។

☑ ចាប់ផ្តើមសន្សំទុកបង្កាន់ដៃប្រាក់ ដែលលោកអ្នកបានចាយទាក់ទង និងការបាត់បង់ដោយ សារអគ្គីភ័យ ។ លោកអ្នកអាចត្រូវការបង្កាន់ដៃនោះ នៅពេលអនាគតឱ្យក្រុមហ៊ុនធានារ៉ាប់រង ហើយដើម្បីបញ្ជាក់មើលការខូចខាត ដូចបានដាក់ឱ្យអនុគ្រោះពន្ធដារ ។

☑ ទាក់ទងនឹងក្រុមហ៊ុនឱ្យប្រាក់ខ្ចីទិញផ្ទះ mortgage ឱ្យដឹងអំពីអគ្គីភ័យ ។

☑ ពិគ្រោះជាមួយគណនេយ្យករ ឬសេវាប្រាក់ចំណូលក្នុងស្រុក (Internal Revenue Service ) អំពីផលប្រយោជន៍ ពិសេសសំរាប់មនុស្សទើបតែងើបរួច ពីការបាត់បង់ទ្រព្យសម្បត្តិ ។

ទំព័លេខទូរស័ព្ទ មាននៅឯកសារមួយផ្សេងទៀត